# មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រឹត្យ


២៧-០១-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០១០៥/០៤០ ស្តីពីការតែងតាំង លោក **ម៉ាន់ សាវេត** ជាឧបនាយកប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី ៣ មានឋានៈ ស្មើអនុរដ្ឋលេខាធិការ ៤៥២

៣១-០១-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០១០៥/០៤៤ ស្តីពីការតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ឆាមរណៈ ជូនសពលោកវរសេនីយ៍ឯក **ឈឹម ប៊ុនធឿន** នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៤៥៣

៣១-០១-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០១០៥/០៤៥ ស្តីពីការផ្ទេរក្របខ័ណ្ឌលោក **សោម សុជាវី** អនុមន្ត្រីថ្នាក់លេខ ៧ នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល មកជាអនុមន្ត្រីថ្នាក់លេខ ៧ នៃក្របខ័ណ្ឌមន្ត្រី រដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ៤៥៤

៣១-០១-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០១០៥/០៤៦ ស្តីពីការប្រោសព្រះរាជទាន ចំពោះឯកឧត្តម **សូរ ឃុន** នូវគ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** ៤៥៥

៣១-០១-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០១០៥/០៤៧ ស្តីពីការបញ្ចប់ភារកិច្ច ឯកឧត្តម **ឈី ឡាយអេង** ពីសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ៤៥៦

៣១-០១-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០១០៥/០៤៨ ស្តីពីការតែងតាំងឯកឧត្តម **អ៊ុច គឹមអន** បច្ចុប្បន្នឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋបារាំង អោយទទួលភារកិច្ចបន្ថែម ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព ប្រចាំប្រទេសក្រិច ដោយមាននិវេសនដ្ឋាន នៅទីក្រុងប៉ារីស ៤៥៧

៣១-០១-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០១០៥/០៤៩ ស្តីពីការតែងតាំងឯកឧត្តម **ហោ ណាំបូរ៉ា** បច្ចុប្បន្ន ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំចក្រភពអង់គ្លេស អោយទទួលភារកិច្ចបន្ថែម ជាឯកអគ្គរាជទូត វិសាមញ្ញ និងពេញសមត្ថភាព ប្រចាំប្រទេសអៀរឡង់ ដោយមាននិវេសនដ្ឋាន នៅទីក្រុងឡុងដ៍ ៤៥៨

០៣-០២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០២០៥/០៥២ ស្តីពីការតែងតាំង ឯកឧត្តម **អេង រ៉ៃឡុង** ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជានិងជាឯកអគ្គរាជទូតគោចរមានឋានៈស្មើរដ្ឋមន្ត្រី ៤៥៩

០៣-០២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០២០៥/០៩៣ ស្តីពីការតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ត្រី ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទចំនួន ០៦ រូប ៤៦០

០៣-០២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០២០៥/០៩៤ ស្តីពីការតែងតាំងជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចំនួន ០៦ រូប មានឋានៈស្មើ **អគ្គនាយក** ៤៦១

## II. ក្រុមប្រឹក្សាធម្មនុញ្ញ

០២-០២-២០០៥ -លិខិតលេខ ០១/២០០៥ កបធ.សជណ ស្តីពី សំណើបកស្រាយមាត្រា ១៥ នៃច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ៤៦៣

## III. រាជរដ្ឋាភិបាល

### ១. អនុក្រឹត្យ

០១-០២-២០០៥ -អនុក្រឹត្យលេខ ០៩ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៤៦៥

០៣-០២-២០០៥ -អនុក្រឹត្យលេខ ១០ អនក្រ.បក ស្តីពីការទទួលស្គាល់វិទ្យាស្ថានគ្រប់គ្រងនៃកម្ពុជា ៤៦៦

០៣-០២-២០០៥ -អនុក្រឹត្យលេខ១១អនក្រ.បក ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់ ៤៦៩

០៧-០២-២០០៥ -អនុក្រឹត្យលេខ ១២ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៤៧២

០៧-០២-២០០៥ -អនុក្រឹត្យលេខ ១៣ អនក្រ.បក ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី ៤៧៤

០១-០២-២០០៥ -អនុក្រឹត្យលេខ ៩៤ អនក្រ.តត ស្តីពីការដាក់ឱ្យមន្ត្រីរាជការចូលនិវត្តន៍ ៤៨៨

០១-០២-២០០៥ -អនុក្រឹត្យលេខ ៩៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៩០

០១-០២-២០០៥ -អនុក្រឹត្យលេខ ៩៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៤៩១

០១-០២-២០០៥ -អនុក្រឹត្យលេខ ៩៧ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៤៩៦

០២-០២-២០០៥ -អនុក្រឹត្យលេខ ៩៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៩៧

០២-០២-២០០៥ -អនុក្រឹត្យលេខ ៩៩អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋអម ទូរគមនាគមន៍កម្ពុជា ៤៩៨

០២-០២-២០០៥ -អនុក្រឹត្យលេខ ១០០ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៥០០

០២-០២-២០០៥ -អនុក្រឹត្យលេខ ១០១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥០១

០២-០២-២០០៥ -អនុក្រឹត្យលេខ ១០២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥០៣

០២-០២-២០០៥ -អនុក្រឹត្យលេខ ១០៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥០៤

០២-០២-២០០៥ -អនុក្រឹត្យលេខ ១០៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥០៥

០៣-០២-២០០៥ -អនុក្រឹត្យលេខ ១០៥ អនក្រ.តត ស្តីពីការតែងតាំងជំនួយការ ៥០៧

០៣-០២-២០០៥ -អនុក្រឹត្យលេខ ១០៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់ ៥០៨
០៣-០២-២០០៥ -អនុក្រឹត្យលេខ ១០៥ អនក្រ.តត ស្តីពីការតែងតាំងជំនួយការ ៥០៧
០៣-០២-២០០៥ -អនុក្រឹត្យលេខ ១០៧អនក្រ.តត ស្តីពីការបញ្ចប់អាណត្តិបេសកកម្មរបស់មន្ត្រីការទូត ៥០៩
០៤-០២-២០០៥ -អនុក្រឹត្យលេខ ១០៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៥១០
០៤-០២-២០០៥ -អនុក្រឹត្យលេខ ១០៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥១៣
០៤-០២-២០០៥ -អនុក្រឹត្យលេខ ១១០ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៥១៤
០៤-០២-២០០៥ -អនុក្រឹត្យលេខ ១១១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥១៦
០៤-០២-២០០៥ -អនុក្រឹត្យលេខ ១១២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥១៧
០៧-០២-២០០៥ -អនុក្រឹត្យលេខ ១១៣ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៥១៩
០៤-០២-២០០៥ -អនុក្រឹត្យលេខ ១១៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៥២០
០៧-០២-២០០៥ -អនុក្រឹត្យលេខ ១១៥ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៥២២
០៧-០២-២០០៥ -អនុក្រឹត្យលេខ ១១៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៥២៥
០៧-០២-២០០៥ -អនុក្រឹត្យលេខ ១១៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥២៩
០៨-០២-២០០៥ -អនុក្រឹត្យលេខ ១១៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥៣០

## ២. សេចក្តីសំរេច

០១-០២-២០០៥ -សេចក្តីសំរេចលេខ ០៨ សសរ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំ និងចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ ៥៣១

## IV. ការងារបណ្តាក្រសួង

### ១. ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

០១-០២-២០០៥ -ប្រកាសលេខ ០៨១ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ភើហ្វេកតា (ខេមបូឌា) ហ្គាមេន បង្កើតរោងចក្រ "កាត់ដេរសំលៀកបំពាក់ នាំចេញ" មានទីតាំងស្ថិតនៅផ្លូវលំ ភូមិត្រពាំងចេក សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ៥៣៥
០១-០២-២០០៥ -ប្រកាសលេខ ០៨២ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ឡូឌុសតិចស្ពាយ ហ្គាមេន (ខេមបូឌា) បង្កើតរោងចក្រ "កាត់ដេរសំលៀកបំពាក់នាំចេញ"មានទី តាំងស្ថិតនៅផ្លូវលំ ភូមិអង្គ ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល ៥៣៧

### ២. ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៣-០២-២០០៥ -ប្រកាសលេខ ០៨៥ MOC/M 2005 ស្តីពីស្ថានភាពរោងចក្រកាត់ដេរមួយចំនួននៅកម្ពុជា ៥៣៩

១១-០១-២០០៥ -លិខិតលេខ ០៦៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**កៅ គីម សាន ខនស្ត្រាក់សិន** ៥៤១

១១-០១-២០០៥ -លិខិតលេខ ០៦៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ធនាគារសាជីវកម្មកម្ពុជា អិលធីឌី** ៥៤៣

១១-០១-២០០៥ -លិខិតលេខ ០៦៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**យី ហេង ខនស្ត្រាក់សិន** ៥៤៥

១១-០១-២០០៥ -លិខិតលេខ ០៧០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ហេង តាយ** ៥៤៧

១២-០១-២០០៥ -លិខិតលេខ ០៧១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ធី.អេស.ខេ ពាណិជ្ជ** ៥៤៩

១២-០១-២០០៥ -លិខិតលេខ ០៧២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អនតិច ត្រេឌីង គីធីអ៊ី អិលធីឌី** ៥៥១

១២-០១-២០០៥ -លិខិតលេខ ០៧៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អិល~ឆូ** ៥៥៣

១២-០១-២០០៥ -លិខិតលេខ ០៧៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អ៊ី ហេង អ៊ីមប៉ិច** ៥៥៥

១២-០១-២០០៥ -លិខិតលេខ ០៧៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឈរីត អាត** ៥៥៧

១២-០១-២០០៥ -លិខិតលេខ ០៧៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**តី អេស ស៊ី កុំព្យូទ័រ សេនធ័រ** ៥៥៩

១២-០១-២០០៥ -លិខិតលេខ ០៧៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អ អេស ខេ ឌីវេឡុបមេន** ៥៦១

១២-០១-២០០៥ -លិខិតលេខ ០៧៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ប្លូ ទើលដ៍** ៥៦៣

១២-០១-២០០៥ -លិខិតលេខ ០៨០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ថាន យ៉ាង ខនស្ត្រាក់សិន ឌីវេឡុបមេន** ៥៦៥

១៣-០១-២០០៥ -លិខិតលេខ ០៨៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ធី អេស អេច គ្រុប គីធីអ៊ី អិលធីឌី** ៥៦៧

១៣-០១-២០០៥ -លិខិតលេខ ០៨០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**តាំង ហុង ហ្វា អ៊ុស្ត ខមភេនី លីមីធីត** ៥៦៩

១៣-០១-២០០៥ -លិខិតលេខ ០៨០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**តាំង ហុង គ្រុប** ៥៧១

១៣-០១-២០០៥ -លិខិតលេខ ០៩២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឡានណា ឌីហ្សាញ ខនស្ត្រាក់សិន (ថៃឡែន)** ៥៧៣

១៣-០១-២០០៥ -លិខិតលេខ ០៩៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ចិបុល រ៉ូយ៉ាល់ (ខេមបូឌា)** ៥៧៥

១៣-០១-២០០៥ -លិខិតលេខ ០៩៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ជូ~លី អគ្រិចឡ្សន់ កសិកម្ម** ៥៧៧

១៤-០១-២០០៥ -លិខិតលេខ ១០០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អេស អិន ស៊ី ស៊ី ឡាថាលីន (ខេមបូឌា) ហូលឌិង លីមីធីត** ៥៧៩

១៤-០១-២០០៥ -លិខិតលេខ ១០១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អាមណៃ គ្រុប** ៥៨១

១៤-០១-២០០៥ -លិខិតលេខ ១០២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អន្តរពិសិដ្ឋ** ៥៨៣

១៤-០១-២០០៥ -លិខិតលេខ ១០៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ស៊ី អិន ស៊ី ខប ផាប់ប្លីក** ៥៨៥

១៤-០១-២០០៥ -លិខិតលេខ ១០៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**វ៉ុក អ៊ិនធើធេនមេន សិនធើ** ៥៨៧

១៤-០១-២០០៥ -លិខិតលេខ ១០៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ស្តែនឌិច អ៊ិនធើណេសិនណល់ (ខេមបូឌា) លីមីធិត** ៥៨៩

១៤-០១-២០០៥ -លិខិតលេខ ១០៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**វ៉ុក ឌូ ហ្គោល (ខេមបូឌា) ខូ អិលធីឌី** ៥៩១

១៤-០១-២០០៥ -លិខិតលេខ ១០៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ខេង រតនា គ្រេឌីង អ៊ិមផត អិចផត** ៥៩៣

១៤-០១-២០០៥ -លិខិតលេខ ១០៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ខេមបូ ប្រាយធើនីង** ៥៩៥

១៤-០១-២០០៥ -លិខិតលេខ ១១០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ស៊ុន ហ៊ួច** ៥៩៧

១៤-០១-២០០៥ -លិខិតលេខ ១១១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឌុច លី ឡាយ អ៊ីម្ពត អិចផត** ៥៩៩

១៤-០១-២០០៥ -លិខិតលេខ ១១៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ប៉េនីនស៊ុឡា ហ្វូដ ឆ៊ិច ខ្លីច ឌីស្ត្រីប៊្យូសិន** ៦០១

១៨-០១-២០០៥ -លិខិតលេខ ១១៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ស្មាត អាយធី ស៊ីលូសិន** ៦០៣

១៨-០១-២០០៥ -លិខិតលេខ ១១៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ប៊ីហ្សនេស សែសស៍ ស៊ីលូសិន** ៦០៥

១៨-០១-២០០៥ -លិខិតលេខ ១២០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ដេ_លែន** ៦០៧

១៨-០១-២០០៥ -លិខិតលេខ ១២៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឥណ្ឌូចិន ឆាយអូ ផ្លាស្ទិក (អាយស៊ីប៊ីភី)** ៦០៩

១៨-០១-២០០៥ -លិខិតលេខ ១២៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អ៊ិន_ឌី_យូ** ៦១១

១៨-០១-២០០៥ -លិខិតលេខ ១២៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ប៉េបេអេសអ៊ី (កំបូជ) អិលធីឌី** ៦១៣

១៨-០១-២០០៥ -លិខិតលេខ ១២៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**តូឡាសាប់ តា អង្គរ ខនស្ត្រាក់សិន** ៦១៥

១៨-០១-២០០៥ -លិខិតលេខ ១៣០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ដេភរ ឃ្លាឡឺរ** ៦១៧

១៨-០១-២០០៥ -លិខិតលេខ ១៣១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ទីត យេត អ៊ិនធើប្រាយ** ៦១៩

១៨-០១-២០០៥ -លិខិតលេខ ១៣២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**យុន ហោងហ៊ួត ខនស្ត្រាក់សិន** ៦២១

១៩-០១-២០០៥ -លិខិតលេខ ១៣៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អិន.អូ.ឌី** ៦២៣

១៩-០១-២០០៥ -លិខិតលេខ ១៣៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឆេង ចំរើន អ៊ីមផត & អិចផត** ៦២៥

១៩-០១-២០០៥ -លិខិតលេខ ១៣៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឡាយ ហៀង ស៊ី ខូ អិលធីឌី** ៦២៧

១៩-០១-២០០៥ -លិខិតលេខ ១៣៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ស៊ីរីសោន** ៦២៩

១៩-០១-២០០៥ -លិខិតលេខ ១៤៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**យូ ហុង គ្រុប** ៦៣១

១៩-០១-២០០៥ -លិខិតលេខ ១៤៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អន្តរគ្រាយដ៏ ខូ អិលធីឌី** ៦៣៣

១៩-០១-២០០៥ -លិខិតលេខ ១៤៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ទើកឃើង អេឡ្រិចលឃាំរ ត្រេដ** ៦៣៥

១៩-០១-២០០៥ -លិខិតលេខ ១៤៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អេស.សេង គ្រុប** ៦៣៧

២០-០១-២០០៥ -លិខិតលេខ ១៥៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឌី អិន អិល គ្លូបិល សឺវីស អាហាំណេ នីហាំណេ & ដឹកជញ្ជូន** ៦៣៩

២០-០១-២០០៥ -លិខិតលេខ ១៥៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**លេហ្សា ជាហ្ស៊ី** ៦៤១

២០-០១-២០០៥ -លិខិតលេខ ១៦០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ហុង យើរ** ៦៤៣

២០-០១-២០០៥ -លិខិតលេខ ១៧០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ដែលតា អិចស៊ីម** ៦៤៥

២០-០១-២០០៥ -លិខិតលេខ ១៧១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**គំងគួ អ៊ិនធើណេសិនណល** ៦៤៧

២០-០១-២០០៥ -លិខិតលេខ ១៧២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**គួ យើង អ៊ិនធើណេសិនណល ត្រេដ** ៦៤៩

២០-០១-២០០៥ -លិខិតលេខ ១៧៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អិល.អ.ធី ស៊ីវីស (ខេមបូឌា)** ៦៥១

២១-០១-២០០៥ -លិខិតលេខ ១៧៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អេ.អូ.ធី ត្រាវែល** ៦៥៣

២១-០១-២០០៥ -លិខិតលេខ ១៧៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អ៊ែសេត (ខេមបូឌា) ខបភើរេសិន** ៦៥៥

២១-០១-២០០៥ -លិខិតលេខ ១៧៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អាយ អឹម ខេ អេឡិចត្រិក** ៦៥៧

២១-០១-២០០៥ -លិខិតលេខ ១៧៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អាឡិចសាន់ អ៊ីន** ៦៥៩

២១-០១-២០០៥ -លិខិតលេខ ១៨១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**បូលីន គ្រុប** ៦៦១

២១-០១-២០០៥ -លិខិតលេខ ១៨២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**តី.អេស.ឌី ត្រេឌីង គ្រុប** ៦៦៣

២១-០១-២០០៥ -លិខិតលេខ ១៨៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឌី.ដាប់បែលយូ.ខេ លីមីធីត** ៦៦៥

២១-០១-២០០៥ -លិខិតលេខ ១៨៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**តាពីម៉ិច គ្រុប** ៦៦៧

២១-០១-២០០៥ -លិខិតលេខ ១៨៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អេស៊ាន ហៅវេច អេជេនស៊ី** ៦៦៩

២១-០១-២០០៥ -លិខិតលេខ ១៨៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អង្គរ ពេត្រូលៀម រីហ្វាញនើរ (អេ.ភី.អ)** ៦៧១

២១-០១-២០០៥ -លិខិតលេខ ១៩០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ហ្វូត សេខ អ៊ីមផត អិចផត** ៦៧៣

២១-០១-២០០៥ -លិខិតលេខ ១៩១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ថៃ ហោ (ខេមបូឌា) អ៊ីន** ៦៧៥

២១-០១-២០០៥ -លិខិតលេខ ១៩៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ធី.ស៊ី ត្រេឌីង ត្រេនស្ពត សឺវិស** ៦៧៧

# ព្រះរាជក្រឹត្យ

នស/រកត/០១០៥/០៤០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់

## ត្រាស់បង្គាប់

**មាត្រា ១.-** តែងតាំងលោក **ឃាន់ សាវ៉េត** ជាឧបការីប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៣ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា ២.-** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣ល.០៥០១.០៤៣

*ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ ២០០៥*

លេខ ៣៩ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible] តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០១០៥/០៤៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ចាមរណៈ ជូនសពលោកវរសេនីយ៍ឯក **នឹម ម៉ុនធឿន** អត្តលេខ ០៣៧៤ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

តរក-០៥០១-០៤៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០០៥

លេខ ៣៦ ច.ល
**ដើម្បីចម្លងចែកចាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ០២ ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឌិត តាន់**

3/2

L Som Sonda

# ព្រះរាជក្រឹត្យ

នស/រកត/០១០៥/០៤៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៣/២១១ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០០៣ ស្តីពីការធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិល ទៅក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានផ្ទេរក្របខ័ណ្ឌ លោក សោម ស៊ីវដា អនុមន្ត្រី ថ្នាក់លេខ៧ នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល មកជាអនុមន្ត្រី ថ្នាក់លេខ ៧ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ភរល.០៥០១.០៤៨

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០០៥

លេខ : ៣៥ ច.ល
[illegible]
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] តាន

/2

# ព្រះរាជក្រឹត្យ

នស/រកត/០១០៥/០៤៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា )

**ប្រោសព្រះរាជទាន**

ចំពោះ

ឯកឧត្តម **សូរ យុន**

នូវ

គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស.០៥០១.០៤៩

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៥*

R.104

លេខ [illegible] ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឈាវី តាន់

12/h

# ព្រះរាជក្រឹត្យ

នស/រកត/០១០៥/០៤៧

យើង

ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/១៧២ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសមាសភាពនៃក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានបញ្ចប់ភារកិច្ច ឯកឧត្តម **លី ឡាយអេង** ពីសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។

**មាត្រា២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៤.០៥០១.០៥០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៥

លេខ ១១៤ ច.ល
ជម្រាបជូនចំពោះ
រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សាន់ ភាន់

៥/២

# ព្រះរាជក្រឹត្យ

នស/រកត/០១០៥/០៤៨

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតួមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** តែងតាំងឯកឧត្តម **អ៊ុង គឹមអាន** បច្ចុប្បន្ន ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋបារាំង អោយទទួលភារកិច្ចបន្ថែម ជាឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព ប្រចាំប្រទេសក្រិច ដោយមានទីស្នាក់ការនៅទីក្រុងប៉ារីស ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ ... ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០.. ខែ ... ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវី តាន់**

០១៤.០៥០១.០៥១

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៥*

2/3

# ព្រះរាជក្រឹត្យ

នស/រកត/០១០៥/០៤៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរាជនា សម្ពោធិ ពុទ្ធិញ្ញាណរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** តែងតាំងឯកឧត្តម ហោ ណាំបូរ៉ា បច្ចុប្បន្ន ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំចក្រភពអង់គ្លេស អោយទទួលភារកិច្ចបន្ថែមជា ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព ប្រចាំប្រទេសអៀកឡង់ ដោយមាននិវេសនដ្ឋាននៅទីក្រុងឡុងដ៏ ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៥

ពាក់ស-០៥០១-០៥៧

លេខ: ៣៧ - ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០០៥
ទីស្តីការគណៈរដ្ឋមន្ត្រី... រដ្ឋាភិបាល

ណាំ តាន់

3/3

# ព្រះរាជក្រឹត្យ

នស/រកត/០២០៥/០៥២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមររាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានតែងតាំងឯកឧត្តម **អេង វ៉ៃឡុច់** ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា និងជាឯកអគ្គរាជទូតគោចរ មានឋានៈស្មើ **រដ្ឋមន្ត្រី** ។

**មាត្រា ២:** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស.០៥០២.០៥៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៥

លេខ ... ច.ល
**ដើម្បីចម្លងចែកជូន**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible]

Created by Chhor Phaly

# ព្រះរាជក្រឹត្យ

នស/រកត/០២០៥/០៥៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជនាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ត្រី ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៦ រូប ដូចមានរាយនាមខាងក្រោម :

១-វរសេនីយ៍ឯក **អ៊ុច សំកត់** អត្តលេខ ០០១២១៤
២-វរសេនីយ៍ឯក **គីម សោភ័ណ្ឌ** អត្តលេខ ០០១២៣៣
៣-វរសេនីយ៍ឯក **ទាន់ ចន្ទ្រៈ** អត្តលេខ ០០៣៣៧២
៤-វរសេនីយ៍ឯក **ម៉ឺន សុខុន** អត្តលេខ ០០៣៩៥០
៥-វរសេនីយ៍ឯក **ម៉ែន ចន្ទភូមិ** អត្តលេខ ០០២២២៥
៦-វរសេនីយ៍ឯក **ហាក់ ម៉ៅ** អត្តលេខ ០២០៩០០

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៥*

*ការ.០៥០២.០៥៦*

លេខ : [illegible] ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវ តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០២០៥/០៥៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតក្ខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតែងតាំងជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ដូចមានរាយនាមខាងក្រោម :

១- ឧត្តមសេនីយ៍ត្រី **ឡៅ សារុន** ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន មានឋានៈស្មើ **អគ្គនាយក**

២- ឧត្តមសេនីយ៍ត្រី **សុខ យាន** ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន មានឋានៈស្មើ **អគ្គនាយក**

៣- ឧត្តមសេនីយ៍ត្រី **សុខ ចារុណ្ណ** ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន មានឋានៈស្មើ **អគ្គនាយក**

៤- ឧត្តមសេនីយ៍ត្រី **សុខ សុវណ្ណ** ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន មានឋានៈស្មើ **អគ្គនាយក**

៥- ឧត្តមសេនីយ៍ត្រី **អ៊ុង សរិទ្ធ** ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន មានឋានៈស្មើ **អគ្គនាយក**

៦- ឧត្តមសេនីយ៍ត្រី គង់ មន្ថា ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩ល.០៥០២.០៥៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៥

លេខ : ៤១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ០២ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សំ ឌី តាន់

3/5

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥

លេខ 01/2005 កបធ. សរ/ឃ

**សូមទូលថ្វាយ**

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រះប្រធានរដ្ឋសភា**

**កម្មវត្ថុ** : សំណើបកស្រាយមាត្រា ១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

**យោង** : - ព្រះរាជចំណារលេខ ០០៥ រស ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៥ របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា

- យោងលិខិតចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៤ របស់លោក **ម៉ុញ នាង**

តបតាមព្រះរាជចំណារដូចមានក្នុងកម្មវត្ថុ និងយោងខាងលើ ទូលបង្គំសូមទូលថ្វាយដូចតទៅ :

សម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៥ បានទទួលព្រះរាជចំណារខាងលើមកពិនិត្យ ហើយយល់ឃើញថា :

១/-មាត្រា ១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញទាក់ទងនឹងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញផង និងសមត្ថកិច្ចរបស់តុលាការផង :

ក- សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលពាក់ព័ន្ធនោះ មានជាអាទិ៍គឺ :បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ ហើយនិងត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ( មាត្រា ១៣៦ ថ្មី និងមាត្រា ១៤១ ថ្មីនៃរដ្ឋធម្មនុញ្ញ ) ។

ខ- សមត្ថកិច្ចរបស់តុលាការ គ្រប់ថ្នាក់ និង គ្រប់ផ្នែក គឺជំនុំជម្រះក្តី (វាក្យខ័ណ្ឌទី ៣ និងទី ៤ នៃមាត្រា ១២៨ ថ្មីនៃរដ្ឋធម្មនុញ្ញ ) ។

-តុលាការត្រូវពិនិត្យមើលពាក្យបណ្តឹងរបស់បុគ្គលដែលមានប្រយោជន៍ក្នុងរឿងក្តី ថាតើពាក្យបណ្តឹងនោះ ស្ថិតក្នុងសមត្ថកិច្ចរបស់អំណាចតុលាការ ឬរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ហើយមានជូនភស្តុតាងបញ្ជាក់គ្រប់គ្រាន់ទេ ។ បើបណ្តឹងនោះ ស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដូចបានបញ្ជាក់ខាងលើ តុលាការសាមីត្រូវលើកករណីនេះជូនទៅតុលាការកំពូលក្នុងរយៈពេល ១០ថ្ងៃ យ៉ាងយូរ ។ តុលាការកំពូលត្រូវចាត់ការពិនិត្យ និងប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ១៥ ថ្ងៃ យ៉ាងយូរ លើកលែងតែតុលាការកំពូលយល់ឃើញថា ពាក្យបណ្តឹងតវ៉ានេះមិនអាចទទួលបាន ។

ផ្ទុយទៅវិញ បើតុលាការថ្នាក់ក្រោមពិនិត្យឃើញថា បណ្តឹងនោះមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ឬគ្មានមូលដ្ឋានគតិយុត្តគ្រប់គ្រាន់ទេនោះ តុលាការត្រូវចាត់ការតាមនីតិវិធីជាធរមាននៃអំណាចតុលាការ ហើយជូនដំណឹងអំពីការសម្រេចរបស់ខ្លួនដល់ម្ចាស់បណ្តឹង ។ ម្ចាស់បណ្តឹងមានសិទ្ធិប្តឹងតទៅទៀតតាមនីតិវិធីជាធរមាននៃអំណាចតុលាការ ។

២/-ក្រុមប្រឹក្សាធម្មនុញ្ញមិនអាចធ្វើបទឧទ្ទេសនាមអំពីអ្វីដែលលោក **ម៉ុស ណាង** បានលើកឡើងក្នុងឧទាហរណ៍របស់លោកនោះទេ ។

សូមសម្តេចក្រុមព្រះ ព្រះប្រធានរដ្ឋសភាទ្រង់ព្រះមេត្តាជ្រាបនិងទទួលនូវគារវភក្តិដ៏ខ្ពង់ខ្ពស់អំពីទូលបង្គំ ។

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

**ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៖ ០៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

************

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧. ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤. ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០.ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១០០៤/ ០០៥ .ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក . ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ១៣២.៤០០.០០០ រៀល ( មួយរយសាមសិបពីរលាន បួនរយពាន់រៀលគត់ ) ពីជំពូក ១៣ ( សកម្មភាពនៃកម្មវិធី ) មកជំពូក ១០ (បៀវត្ស និង ប្រាក់បំណាច់ ) របស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៤ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយបើកប្រាក់បំណាច់ម៉ោងបន្ថែមនិងប្រាក់រង្វាន់តរុកោសល្យ ឆ្នាំ ២០០៤ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីគោរពជូន**
**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**
**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៦៦.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការទទួលស្គាល់វិទ្យាស្ថានគ្រប់គ្រងនៃកម្ពុជា

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី [illegible] ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញលិខិតស្នើសុំ របស់លោក មុំ រិរិន ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៤
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១ :** ទទួលស្គាល់ គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា **វិទ្យាស្ថានគ្រប់គ្រងនៃកម្ពុជា**

**"Management Institute of Cambodia"** ហៅកាត់ជាភាសាខ្មែរ វ.គ.ក. និងហៅកាត់ជាភាសាអង់គ្លេស M.I.C. ។

**មាត្រា ២** : វិទ្យាស្ថានគ្រប់គ្រងនៃកម្ពុជា មានទីតាំងស្ថិតនៅផ្ទះលេខ ៦៥ A+B+C+D ផ្លូវមុន្នីរ៉េត សង្កាត់ផ្សារដើមគរ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ និងស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៣** : វិទ្យាស្ថានគ្រប់គ្រងនៃកម្ពុជា ធ្វើការបណ្តុះបណ្តាល :

- ថ្នាក់បរិញ្ញាបត្ររង សិក្សារយៈពេល ២ឆ្នាំ ជាមធ្យម
- ថ្នាក់បរិញ្ញាបត្រ សិក្សារយៈពេល ៤ឆ្នាំ ជាមធ្យម ។

**មាត្រា ៤** : វិទ្យាស្ថានគ្រប់គ្រងនៃកម្ពុជា មាន :

- មហាវិទ្យាល័យនីតិសាស្ត្រ និងភាសាបរទេស
- មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងព័ត៌មានវិទ្យា ។

ទៅអនាគត វិទ្យាស្ថាននេះ អាចបើកមហាវិទ្យាល័យ សាខា ឯកទេស ឬ ប្រភេទបណ្តុះបណ្តាលដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាត ពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៥** : វិទ្យាស្ថានគ្រប់គ្រងនៃកម្ពុជា មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេច លើគោលនយោបាយ ផែនការអភិវឌ្ឍន៍ កម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត ។

**មាត្រា ៦** : តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង របស់វិទ្យាស្ថានគ្រប់គ្រងនៃកម្ពុជា ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន ដោយមានការឯកភាព ពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៧** : នាយកនៃវិទ្យាស្ថានគ្រប់គ្រងនៃកម្ពុជា មានភារកិច្ច :

- ទទួលខុសត្រូវនៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងវិទ្យាស្ថាន
- ជ្រើសរើសសិស្ស-និស្សិតឱ្យចូលរៀន ជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និងបុគ្គលិកមកបម្រើការងារ
- គ្រប់គ្រងឱ្យបានល្អ នូវការងារបណ្តុះបណ្តាល ការងារស្រាវជ្រាវ ការប្រលង និងការប្រគល់សញ្ញាបត្រ
- គោរព និងអនុវត្តតាមច្បាប់ និងបទដ្ឋាននានា ដែលពាក់ព័ន្ធនឹងការងារបណ្តុះបណ្តាលរបស់រាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា
- ធានាឱ្យបាននូវសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម
- ធ្វើរបាយការណ៍រាល់សកម្មភាពសិក្សា និងការគ្រប់គ្រងការងារបណ្តុះបណ្តាល ជូននាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា ឱ្យបានទៀងទាត់តាមពេលកំណត់ ។

**មាត្រា ៨** : និស្សិតដែលបានរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថានគ្រប់គ្រងនៃកម្ពុជា និងទទួលបានជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សាត្រូវទទួលសញ្ញាបត្រតាមកម្រិតនិងតាមឯកទេសដែលបានសិក្សា ។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយវិទ្យាស្ថានគ្រប់គ្រងនៃកម្ពុជា ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីវិទ្យាស្ថាន បានបំពេញ អនុវត្តតាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៩ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អគ្គនាយកដ្ឋានអង្គភាពពាក់ព័ន្ធ និងវិទ្យាស្ថានគ្រប់គ្រងនៃកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ០៣ ខែ ០១ ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ
  " ដើម្បីមុខការ"
- ដូចមាត្រា ៩ "ដើម្បីអនុវត្ត"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៥ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- យោងតាមស្មារតីអង្គប្រជុំលើកទី ១៩ របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៤
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សំរេច

**មាត្រា ១ :**

អនុលោមតាមមាត្រា ៧៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ កំរិតនៃការផ្ទេរពីចំណូលចរន្តនៃថវិការដ្ឋទៅក្នុងគណនីមូលនិធិឃុំ សង្កាត់ មានដូចខាងក្រោម :

- ឆ្នាំថវិកា ២០០៥ : ២,៥២ ភាគរយ នៃចំណូលចរន្តរបស់ថវិការដ្ឋ

- ឆ្នាំថវិកា ២០០៦ : ២.៥៤ ភាគរយ នៃចំណូលចរន្តរបស់ថវិកាជាតិ
- ឆ្នាំថវិកា ២០០៧ : ២.៥៦ ភាគរយ នៃចំណូលចរន្តរបស់ថវិកាជាតិ

**មាត្រា ២ :**

ការផ្ទេរថវិកាជាតិប្រចាំឆ្នាំទៅក្នុងគណនីមូលនិធិឃុំ សង្កាត់ និងការផ្ទេរពីគណនីមូលនិធិឃុំ សង្កាត់ទៅគណនីប្រាក់បញ្ញើរបស់ឃុំ សង្កាត់នីមួយៗ ត្រូវអនុវត្តជាបណ្តើរៗ ដោយផ្អែកលើលទ្ធភាពនៃការប្រមូលចំណូលថវិកាជាតិ និងកំណត់ដូចខាងក្រោម :

- យ៉ាងតិច ៥០ភាគរយ នៃចំនួនផ្ទេរសរុប រហូតដល់ថ្ងៃទី ៣១ ខែ ឧសភា
- យ៉ាងតិច ៨០ភាគរយ នៃចំនួនផ្ទេរសរុប រហូតដល់ថ្ងៃទី ៣១ ខែ សីហា
- និង ១០០ភាគរយ នៃចំនួនផ្ទេរសរុប រហូតដល់ថ្ងៃទី ៣១ ខែ តុលា

**មាត្រា ៣ :**

ឃុំ សង្កាត់ទាំងអស់ ត្រូវទទួលបានធនធានមូលនិធិសំរាប់រដ្ឋបាលទូទៅ និងសំរាប់អភិវឌ្ឍន៍ ។

ធនធានមូលនិធិដែលផ្តល់សំរាប់សមាសភាគរដ្ឋបាលទូទៅ មិនត្រូវច្រើនជាង ១/៣ ( មួយភាគបី ) នៃធនធានមូលនិធិសរុប ។

ធនធានមូលនិធិដែលផ្តល់សំរាប់សមាសភាគអភិវឌ្ឍន៍មូលដ្ឋាន មិនត្រូវតិចជាង ២/៣ ( ពីរភាគបី ) នៃធនធានមូលនិធិសរុប ។

**មាត្រា ៤ :**

ធនធាននៃសមាសភាគរដ្ឋបាលទូទៅ ត្រូវបានប្រើប្រាស់សំរាប់ការចំណាយទាំងឡាយ ដូចបានចែងក្នុងកថាខ័ណ្ឌទី ២ មាត្រា ១៥ នៃអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់ និងសំរាប់ចំណាយឧបត្ថម្ភដល់មន្ត្រីភូមិ តាមរបបកំណត់ជាធរមាន ។

ធនធាននៃសមាសភាគរដ្ឋបាលទូទៅរួមមាន ចំណាយសំរាប់ប្រតិបត្តិការរដ្ឋបាល ចំណាយសំរាប់ប្រាក់បំណាច់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងចំណាយសំរាប់ឧបត្ថម្ភមន្ត្រីភូមិ ។

ចំណាយសំរាប់ប្រតិបត្តិការរដ្ឋបាល ត្រូវបានគណនាដោយយកសរុបធនធាននៃសមាសភាគរដ្ឋបាលទូទៅដកចេញនូវចំណាយសំរាប់ប្រាក់បំណាច់ក្រុមប្រឹក្សាឃុំ សង្កាត់ និងចំណាយសំរាប់ឧបត្ថម្ភមន្ត្រីភូមិ រួចទើបធ្វើការបែងចែកទៅតាមសមាមាត្រនៃចំនួនក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ។

**មាត្រា ៥ :**

ធនធាននៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន ត្រូវបានប្រើប្រាស់សំរាប់ការចំណាយទាំងឡាយ ដូចបានចែងក្នុងកថាខ័ណ្ឌទី ៣ មាត្រា ១៥ នៃអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់ និងត្រូវបានបែងចែកទៅអោយឃុំ សង្កាត់នីមួយៗ តាមការគណនាដោយផ្អែកលើសន្ទស្សន៍ដូចខាងក្រោម :

- ចំណែកស្មើគ្នាជាមូលដ្ឋាន
- ចំនួនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់នីមួយៗ ( ឯកសាររបស់ក្រសួងផែនការ )
- សន្ទស្សន៍ភាពក្រីក្រនៃឃុំ សង្កាត់នីមួយៗ ( ឯកសាររបស់ក្រសួងផែនការ )
- សន្ទស្សន៍ផ្សេងៗទៀត តាមការកំណត់របស់ក្រុមប្រឹក្សាភិបាលមូលនិធិឃុំ សង្កាត់

សមាមាត្រនៃមូលនិធិសំរាប់អភិវឌ្ឍន៍មូលដ្ឋាន សំរាប់សន្ទស្សន៍នីមួយៗខាងលើនេះ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលមូលនិធិឃុំ សង្កាត់ ។

**មាត្រា ៦ :**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៧ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលគ្រប់ខេត្ត ក្រុង ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

**ស ខេង** **នរោត្តម សិរីវុឌ្ឍ**

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**គាត ឈន់**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ចំលងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

************

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧, ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤, ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០.ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១០០៤/ ០០៥ .ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក , ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបែងចែកចំណាយថវិកាខ្ទង់ទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៧២០ លានរៀល ( ប្រាំពីររយម្ភៃ លានរៀលគត់ ) ពីជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច ) មកជំពូក ១០ (បៀវត្ស និង ប្រាក់បំណាច់ ) របស់ក្រសួងមហាផ្ទៃ "ផ្នែករដ្ឋបាលទូទៅ" សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៤ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយបើកប្រាក់បៀវត្សជូនមន្ត្រីរាជការ ឆ្នាំ ២០០៤ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ✓
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីជំរាបជូន**
**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**
**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១០៥ / ០០២ ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៥

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់ការរៀបចំបណ្តាអង្គភាពនៃក្រសួងកិច្ចការនារី និងកំណត់បេសកកម្មរបស់គ្រប់អង្គភាពទាំងមុខការ នៃអគ្គាធិការដ្ឋាន អគ្គនាយកដ្ឋាន និងនាយកដ្ឋាននានា ។

## ជំពូកទី ២

## បេសកកម្ម និង រចនាសម្ព័ន្ធ

**មាត្រា ២.-**

ក្រសួងកិច្ចការនារី ត្រូវរាជរដ្ឋាភិបាលកម្ពុជា ប្រគល់បេសកកម្មឱ្យដឹកនាំ និងគ្រប់គ្រងលើវិស័យកិច្ចការនារី នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.-**

**ក្រសួងកិច្ចការនារី មានមុខងារ និងភារកិច្ចដូចតទៅ :**

-ធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយជាតិ ដើម្បីធានាឱ្យស្ត្រីទទួលបាននូវផលប្រយោជន៍ដូចបុរស និងលើកកម្ពស់ស្ថានភាពរបស់ស្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

-ជំរុញ សម្របសម្រួល តស៊ូមតិដើម្បីស្វែងរកការគាំទ្រ តាមដាននិងត្រួតពិនិត្យវាយតម្លៃការអនុវត្តគោលនយោបាយជាតិ និងកម្មវិធីផ្សេងៗ ក្នុងគោលដៅលើកកម្ពស់ស្ថានភាពស្ត្រី

-សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័ន អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ មន្ទីរខេត្ត-ក្រុង ក្រុមប្រឹក្សាឃុំ-សង្កាត់ គណៈកម្មការអភិវឌ្ឍន៍ដែលពាក់ព័ន្ធនានា ដើម្បីបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយជាតិ គោលនយោបាយមូលដ្ឋាន និងកម្មវិធីផ្សេងៗ ព្រមទាំងដើម្បីបង្កើនសមាមាត្រនៃការចូលរួមរបស់ស្ត្រីឱ្យបានជាអតិបរមាក្នុងក្រសួង ស្ថាប័នជាតិគ្រប់ថ្នាក់ តាំងពីថ្នាក់កណ្តាល រហូតដល់មូលដ្ឋាន

-សិក្សា ស្រាវជ្រាវ រៀបចំគោលនយោបាយ និងកម្មវិធីផ្សេងៗ ដើម្បីកាត់បន្ថយគម្លាតយេនឌ័រ និងបង្កើនឋានៈតួនាទីរបស់ស្ត្រី

-សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិលជំរុញដំណើរការកម្មវិធីជួយដល់ស្ត្រី ជាពិសេសស្ត្រីចាស់ជរា ឬគ្មានទីពឹង ឬពិការ ឬមេម៉ាយ ស្ត្រីនិងកុមាររងគ្រោះដោយជម្ងឺអេដស៍ ដោយការជួញដូរ រងគ្រោះពីរាល់ទម្រង់នៃអំពើហិង្សាប្រឆាំងនឹងស្ត្រី រួមមានការចាប់រំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារជាដើម

-ចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ តាមរយៈការលើកកម្ពស់ការអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យម ផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ផ្តល់លទ្ធភាពក្នុងការទទួលនូវសេវាឥណទាន និងបង្កើតមុខរបរ សម្រាប់ស្ត្រី

-រៀបចំកម្មវិធីអប់រំ និងផ្សព្វផ្សាយព័ត៌មាន ប្រឆាំងនឹងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងការពារជនរងគ្រោះ

-ជំរុញឱ្យស្ត្រីនិងកុមារទទួលនូវសិទ្ធិការពារតាមផ្លូវច្បាប់ និងដោយយុត្តិធម៌ តាមរយៈការធ្វើជាអ្នកដើមបណ្តឹងជូសមុខឱ្យជនរងគ្រោះទៅតុលាការ និងការដាក់បញ្ចូលទៅក្នុងច្បាប់ ការអនុវត្តច្បាប់ ការបណ្តុះបណ្តាល ការផ្សព្វផ្សាយ និងការអប់រំឱ្យបានជាអតិបរមា

-ជំរុញឱ្យស្ត្រីនិងកុមារទទួលការថែទាំសុខភាពបឋម ការប្រើប្រាស់ សេវាថែទាំក្នុងការធ្វើឱ្យប្រសើរឡើងនូវសុខមាលភាព ជាពិសេសសុខភាពបន្តពូជ និងការទប់ស្កាត់ការឆ្លងមេរោគអេដស៍និងជំងឺអេដស៍ និងការលើកស្ទួយស្ថានភាពអាហារូបត្ថម្ភរបស់ស្ត្រីនិងកុមារ

-ជំរុញការចូលរៀន និងកាត់បន្ថយការបោះបង់ចោលការសិក្សារបស់សិស្សស្រីនៅគ្រប់កម្រិត ចាប់ពីបឋមសិក្សារហូតដល់ឧត្តមសិក្សា ព្រមទាំងបង្កើនអក្ខរភាពនិងជំនាញរបស់ស្ត្រី

-លើកកម្ពស់សីលធម៌សង្គម និងតម្លៃគ្រួសារខ្មែរ តាមរយៈការផ្សព្វផ្សាយព័ត៌មានគ្រប់រូបភាព ដូចជាឯកសារបោះពុម្ព វិទ្យុ ទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទំនើប ។ល។ និងលើកទឹកចិត្តស្ត្រីឱ្យចូលរួមក្នុងការរៀបចំកម្មវិធីនេះ

-ជំរុញការអនុវត្តអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារី ដែលព្រះរាជាណាចក្រកម្ពុជា ជាភាគីហត្ថលេខី នាថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩២ និងពិធីសារអង្គការសហប្រជាជាតិ ស្តីពីការទប់ស្កាត់ ការបង្ក្រាបនិងការដាក់ទណ្ឌកម្ម ការជួញដូរមនុស្ស ពិសេសស្ត្រីនិងកុមារ បំពេញបន្ថែមឱ្យអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ដែលមានការចាត់តាំង ព្រមទាំងច្បាប់និងអនុសញ្ញាអន្តរជាតិ ដទៃទៀត ដែលការពារសិទ្ធិ និងផលប្រយោជន៍របស់ស្ត្រី និងកុមារ ។

**មាត្រា ៤.-**

ក្រសួងកិច្ចការនារី មានរចនាសម្ព័ន្ធដូចតទៅ :

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អគ្គាធិការដ្ឋាន
- អគ្គនាយកដ្ឋាន រដ្ឋបាលនិងកិច្ចការទូទៅ
- អគ្គនាយកដ្ឋាន សមភាពយេនឌ័រនិងអភិវឌ្ឍសេដ្ឋកិច្ច
- អគ្គនាយកដ្ឋាន អភិវឌ្ឍសង្គម
- អង្គភាពមូលដ្ឋាន
- មជ្ឈមណ្ឌលអភិវឌ្ឍស្ត្រី

អង្គការលេខរបស់ក្រសួងកិច្ចការនារី ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ៣

## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា ៥.-**

ខុទ្ទកាល័យរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលកំណត់តាមបទប្បញ្ញត្តិ នៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ដូចមានយោងក្នុងមូលបទខាងលើស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន ។

## ជំពូកទី ៤

## អគ្គាធិការដ្ឋាន

**មាត្រា ៦.-**

អគ្គាធិការដ្ឋាន មានភារកិច្ចធ្វើជាសេនាធិការជូនក្រសួងលើការងារដូចតទៅ :

-ធ្វើអធិការកិច្ចលើគ្រប់អង្គភាពក្រោមឱវាទក្រសួងកិច្ចការនារី

-ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី ពីការប្រព្រឹត្តទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចហើយនោះ និងមធ្យោបាយកែលម្អអំពីការប្រព្រឹត្តទៅរបស់អង្គភាពទាំងនោះ

-ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តច្បាប់ពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួង

-អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងបានប្រគល់ជូន ។

អគ្គាធិការដ្ឋាន ដឹកនាំដោយអគ្គាធិការមួយរូបនិងមានអគ្គាធិការរងមួយចំនួនជាជំនួយការតាមការចាំបាច់ ។

## ជំពូកទី ៥

## អគ្គនាយកដ្ឋាន រដ្ឋបាលនិងកិច្ចការទូទៅ

**មាត្រា ៧.-**

អគ្គនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ មានភារកិច្ចធ្វើជាសេនាធិការជូនក្រសួងលើការងារ :

-គ្រប់គ្រងការងាររួមមាន: រដ្ឋបាល បូកសរុប របាយការណ៍ ឯកសារ បុគ្គលិក ផែនការ ហិរញ្ញវត្ថុ សម្ភារៈ បរិក្ខារ ការងារបណ្តុះបណ្តាលក្របខ័ណ្ឌក្រសួង ការងារសិក្សាស្រាវជ្រាវ និងធ្វើតុល្យភាពការងារ

-សម្របសម្រួលរាល់សកម្មភាពរដ្ឋបាល នៅក្នុងក្រសួងជាមួយបណ្តាអង្គភាពមូលដ្ឋានខេត្ត-ក្រុង និងជាមួយបណ្តាក្រសួង ស្ថាប័ននានា

-អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

អគ្គនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ ដឹកនាំដោយអគ្គនាយកមួយរូបដែលមានអគ្គនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ មាននាយកដ្ឋានចំណុះចំនួន៣ ដូចខាងក្រោម :

-នាយកដ្ឋាន រដ្ឋបាល បុគ្គលិក

-នាយកដ្ឋាន ហិរញ្ញវត្ថុនិងផ្គត់ផ្គង់

-នាយកដ្ឋាន ផែនការនិងស្ថិតិ

**មាត្រា ៨.-**

**នាយកដ្ឋាន រដ្ឋបាលបុគ្គលិក** មានភារកិច្ច :

-សម្របសម្រួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្តាល រវាងថ្នាក់កណ្តាលនិងអង្គភាពមូលដ្ឋានក្រោមឱវាទរបស់ក្រសួង និងជាមួយអន្តរក្រសួង

-គ្រប់គ្រងនិងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង

-គ្រប់គ្រងយានដ្ឋាននិងយានយន្តរបស់ក្រសួង

-ធានាប្រសិទ្ធភាពរដ្ឋបាល និងសុវត្ថិភាពទ្រព្យសម្បត្តិរបស់ក្រសួង

-រៀបចំ សម្របសម្រួលពិធីបុណ្យជាតិ អន្តរជាតិដែលពាក់ព័ន្ធ និងការប្រជុំជាប្រចាំនៅក្នុងក្រសួង

- ធ្វើរបាយការណ៍ការងារ និងធ្វើកំណត់ហេតុអង្គប្រជុំរបស់ក្រសួង

-ទទួលបន្ទុកការងារពិធីការ និងទំនាក់ទំនងអន្តរជាតិ

-គ្រប់គ្រង ជ្រើសរើស និងវាយតម្លៃតំឡើងឋានៈមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យាដោយធ្វើទំនាក់ទំនងជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-រៀបចំបែបបទរដ្ឋបាល និងគ្រប់គ្រងឯកសារ ពាក់ព័ន្ធនឹងបុគ្គលិករបស់ក្រសួង

-ប៉ាន់ប្រមាណពីតម្រូវការក្នុងការបណ្តុះបណ្តាលមន្ត្រីរាជការ និងសម្របសម្រួល ឱ្យមន្ត្រីរាជការទទួលបានការបណ្តុះបណ្តាល

-គ្រប់គ្រងស្ថិតិបុគ្គលិក និងតារាងព័ត៌មានប្រតិបត្តិ

-រៀបចំការងារបៀវត្សពលកម្ម និងប្រាក់កម្រៃផ្សេងៗជូនមន្ត្រីរាជការក្រោមឱវាទក្រសួង ។

នាយកដ្ឋានរដ្ឋបាល បុគ្គលិក ដឹកនាំដោយប្រធានមួយរូបដែលមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

**មាត្រា ៩.-**

**នាយកដ្ឋាន ហិរញ្ញវត្ថុនិងផ្គត់ផ្គង់** មានភារកិច្ច :

-រៀបចំគម្រោងថវិកាក្រសួង និងតាមដានវិលិកពីការប្រតិបត្តិ

-ប្រមូលផ្តុំនិងសម្របសម្រួលជំពូកថវិកា

-ប្រមូលផ្តុំនិងសម្របសម្រួលរាល់ការចំណាយរបស់ក្រសួង

-តាមដានរំលឹកការគ្រប់គ្រងគណនីពិសេស

-រៀបចំឯកសារនិងសម្របសម្រួលការអនុវត្តកិច្ចសន្យា កិច្ចព្រមព្រៀងនានា

-សហការជាមួយអ្នកផ្តល់ជំនួយ និងប្រតិបត្តិការជំនួយអន្តរជាតិ

-សហការជាមួយអង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

-ប្រមូលផ្តុំតម្រូវការបរិក្ខារ ធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំជួសជុលសម្ភារៈ បរិក្ខារ និងយានយន្ត របស់ក្រសួង

-គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ

-បែងចែកសម្ភារៈ បរិក្ខារ និងប្រេងឥន្ធនៈជូនបណ្តាអង្គភាពក្រោមឱវាទក្រសួង

-កាន់បញ្ជីជាប្រចាំនូវសាលាកប័ត្រ និងគណនេយ្យរូបធាតុ

-រៀបចំប្រព័ន្ធព័ត៌មានវិទ្យា នៃសកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី

-គ្រប់គ្រងបន្ទុកគណនី ត្រួតពិនិត្យបច្ចេកទេស នៃការប្រតិបត្តិលទ្ធកម្មសាធារណៈ ។

នាយកដ្ឋានហិរញ្ញវត្ថុនិងផ្គត់ផ្គង់ ដឹកនាំដោយប្រធានមួយរូបដែលមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

**មាត្រា ១០.-**

**នាយកដ្ឋាន ផែនការនិងស្ថិតិ** មានភារកិច្ច :

-ប្រមូលនិងវិភាគព័ត៌មាននិងស្ថិតិនារីតាមវិស័យនានា ដោយសហការផ្ទាល់ជាមួយអង្គភាពក្រោមឱវាទក្រសួង និងស្ថាប័នពាក់ព័ន្ធ

-កំណត់រកចំណុចខ្វះចន្លោះ និងចុះកិច្ចសន្យាជាមួយស្ថាប័នខាងក្រៅក្នុងការធ្វើការស្រាវជ្រាវ ដើម្បីបង្កើនការយល់ដឹងអំពីបញ្ហាយេនឌ័រ សម្រាប់ការរៀបចំគោលនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល និងកម្មវិធីអាទិភាពរបស់ក្រសួង

-រៀបចំកម្មវិធីវិនិយោគសាធារណៈ ដោយសហការជាមួយអង្គភាពពាក់ព័ន្ធដើម្បីផលប្រយោជន៍ស្ត្រី

-សម្របសម្រួលក្នុងការរៀបចំឯកសារក្របខ័ណ្ឌចំណាយសាធារណៈរយៈពេលមធ្យម ដោយសហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីគាំទ្រសកម្មភាពការងារ និងកម្មវិធីអភិវឌ្ឍស្ត្រី

-សម្របសម្រួលការរៀបចំថវិកា

-តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាព និងកំណត់ទិសដៅអភិវឌ្ឍស្ត្រី

-គ្រប់គ្រងឯកសារស្តីពីគម្រោងជំនួយ និងស្ថានភាពនៃការអនុវត្តគម្រោងរបស់អ្នកផ្តល់ជំនួយក្នុងវិស័យកិច្ចការនារី និងចងក្រងឯកសារទិន្នន័យមូលដ្ឋានស្តីពីគម្រោងជំនួយ

-រៀបចំរបាយការណ៍សម្រាប់ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ក្រសួងផែនការ និងរបាយការណ៍បញ្ចប់អាណត្តិ ដោយសហការជាមួយអង្គភាពចំណុះក្រសួង

-គ្រប់គ្រងមជ្ឈមណ្ឌលព័ត៌មានស្ត្រី ។

នាយកដ្ឋានផែនការនិងស្ថិតិ ដឹកនាំដោយប្រធានមួយរូបដែលមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

## ជំពូកទី ៦

## អគ្គនាយកដ្ឋាន សមភាពយេនឌ័រនិងអភិវឌ្ឍសេដ្ឋកិច្ច

**មាត្រា ១១.-**

អគ្គនាយកដ្ឋានសមភាពយេនឌ័រនិងអភិវឌ្ឍសេដ្ឋកិច្ច មានភារកិច្ចធ្វើជាសេនាធិការជូនក្រសួង លើការងារ :

-ទំនាក់ទំនង សម្របសម្រួល គ្រប់គ្រងការងារ ព័ត៌មាន ផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានទំនើប ដើម្បីលើកកម្ពស់ សីលធម៌ សង្គមនិងតម្លៃគ្រួសារខ្មែរ សមភាពយេនឌ័រ និងអភិវឌ្ឍសេដ្ឋកិច្ចសម្រាប់ស្ត្រី

-អនុវត្តគោលនយោបាយយេនឌ័រ តាមរយៈការបន្តអនុវត្តនូវផែនការយុទ្ធសាស្ត្រនារីរតនៈទី ២ និងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រតាមរយៈការអភិវឌ្ឍសេដ្ឋកិច្ចសម្រាប់ស្ត្រី

-អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ជូន ។

អគ្គនាយកដ្ឋានសមភាពយេនឌ័រនិងអភិវឌ្ឍសេដ្ឋកិច្ច ដឹកនាំដោយអគ្គនាយកមួយរូបដែលមានអគ្គនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់។

អគ្គនាយកដ្ឋានសមភាពយេនឌ័រនិងអភិវឌ្ឍសេដ្ឋកិច្ចមាននាយកដ្ឋានចំណុះចំនួន ៣ ដូចខាងក្រោម :

-នាយកដ្ឋាន ព័ត៌មាន

-នាយកដ្ឋាន សមភាពយេនឌ័រ

-នាយកដ្ឋាន អភិវឌ្ឍសេដ្ឋកិច្ច

**មាត្រា ១២.-**

**នាយកដ្ឋាន ព័ត៌មាន** មានភារកិច្ច :

-ផលិតផ្សព្វផ្សាយព័ត៌មាន និងឯកសារផ្សេងៗដែលទាក់ទងនឹងសកម្មភាពនយោបាយ សេដ្ឋកិច្ចសង្គម វប្បធម៌ ដែលជាស្នាដៃសកម្មភាពពិតរបស់នារី តាមរយៈប្រព័ន្ធផ្សព្វផ្សាយគ្រប់ប្រភេទ

-ទំនាក់ទំនងជាមួយគ្រប់បណ្តាញព័ត៌មាន ប្រព័ន្ធផ្សព្វផ្សាយជាតិនិងអន្តរជាតិនានា ដើម្បីជំរុញការផ្សព្វផ្សាយប្រកបដោយគុណភាពខ្ពស់

-បោះពុម្ពនិងចែកផ្សាយឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងបេសកកម្មរបស់ក្រសួង ដោយសហការជាមួយក្រសួង ស្ថាប័ន អង្គការក្រៅរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយនានា

-សហការជាមួយ ក្រសួង ស្ថាប័ន អង្គការ សមាគម ពាក់ព័ន្ធដើម្បីលើកកម្ពស់សីលធម៌សង្គម និងតម្លៃគ្រួសារខ្មែរតាមរយៈការផ្សព្វផ្សាយអប់រំ

នាយកដ្ឋានព័ត៌មាន ដឹកនាំដោយប្រធានមួយរូបដែលមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

**មាត្រា ១៣..-**

**នាយកដ្ឋាន សមភាពយេនឌ័រ** មានភារកិច្ច :

-សិក្សាស្រាវជ្រាវរៀបចំគោលការណ៍ និងគោលនយោបាយ ស្តីពីការបញ្ជ្រាបយេនឌ័រ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន

-ជំរុញតាមដាននិងវាយតម្លៃការរីកចម្រើន និងចូលរួមសរសេររបាយការណ៍ស្តីពីគោលនយោបាយជាតិ

-សម្របសម្រួលផ្តល់ជំនួយបច្ចេកទេស ស្តីពីការបញ្ជ្រាបយេនឌ័រដល់ស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ខេត្ត-ក្រុង ថ្នាក់ឃុំ-សង្កាត់ ដើម្បីបង្កើនភាពអង់អាចដល់ស្ត្រី

-សហការជាមួយអង្គការជាតិ អន្តរជាតិ ដែលធ្វើការងារពាក់ព័ន្ធនឹងវិស័យយេនឌ័រ ដើម្បីផ្តល់ព័ត៌មាន និងផ្លាស់ប្តូរបទពិសោធន៍

-ទំនាក់ទំនង និងតាមដានការអនុវត្តកម្មវិធីនានា និងគាំទ្រដល់ក្រុមការងារបច្ចេកទេសយេនឌ័រ

-ពង្រឹងសមត្ថភាពដល់ស្ត្រី និងតស៊ូមតិដើម្បីស្វែងរកការគាំទ្រ ពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីឱ្យមានស្ត្រីកាន់តែច្រើនចូលរួមក្នុងការធ្វើការសម្រេចចិត្តនៅគ្រប់កម្រិត

-សិក្សាស្រាវជ្រាវជំរុញ និងស្វែងរកការគាំទ្រឱ្យមានការជ្រើសរើស និងការតម្លើងឋានៈស្ត្រីក្នុងស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល និងផ្នែកឯកជនកាន់តែច្រើនឡើង

-ស្វែងរកការគាំទ្រឱ្យមានការឆ្លើយតបទៅនឹងសមភាពយេនឌ័រនៅក្នុងគោលនយោបាយ និងកម្មវិធីរបស់រាជរដ្ឋាភិបាលនិងអ្នកផ្តល់ជំនួយ

-សម្របសម្រួលនិងសហការក្នុងការធ្វើរបាយការណ៍ទៅអាស៊ាន និងអង្គការសហប្រជាជាតិ ស្របតាមការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងទំនាក់ទំនងអន្តរជាតិ

នាយកដ្ឋានសមភាពយេនឌ័រ ដឹកនាំដោយប្រធានមួយរូបដែលមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

**មាត្រា ១៤.-**

**នាយកដ្ឋាន អភិវឌ្ឍសេដ្ឋកិច្ច** មានភារកិច្ច :

-សិក្សាស្រាវជ្រាវ អំពីតម្រូវការរបស់គ្រួសារ និងធនធានមូលដ្ឋាន ដើម្បីលើកកម្ពស់កម្រិតសេដ្ឋកិច្ចរបស់ស្ត្រីនៅក្នុងសហគមន៍

-សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធធ្វើការបណ្តុះបណ្តាលនារីនៅតាមសហគមន៍ឱ្យមានមុខរបរដើម្បីបង្កើនប្រាក់ចំណូលសម្រាប់គ្រួសារ

-សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធរៀបចំកម្មវិធីបណ្តុះបណ្តាលសម្រាប់មជ្ឈមណ្ឌលអភិវឌ្ឍស្ត្រី ផ្តល់ជំនាញបំណិនជីវិត និងអក្ខរកម្មដល់ស្ត្រី

-ធ្វើឱ្យប្រសើរឡើងនូវស្ថានភាពរស់នៅក្នុងគ្រួសារ និងសហគមន៍តាមរយៈការផ្តល់លទ្ធភាព ឱ្យទទួលបានទុន និងជំនួយបច្ចេកទេសសម្រាប់ជំនួញខ្នាតតូច និងមធ្យម ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល និងផ្នែកឯកជន

-សម្របសម្រួលដើម្បីទទួលការណែនាំសម្រាប់ការអភិវឌ្ឍ និងការកែច្នៃផលិតផលឱ្យប្រណិតសម្រាប់ទីផ្សារជាតិ និងអន្តរជាតិ

-បន្តកម្មវិធីឥណទាន ផ្តល់ការបណ្តុះបណ្តាលដល់ភ្នាក់ងារគ្រប់កម្រិតនិងប្រែក្លាយកម្មវិធីនេះទៅជាស្ថាប័នមីក្រូហិរញ្ញវត្ថុ

នាយកដ្ឋានអភិវឌ្ឍសេដ្ឋកិច្ច ដឹកនាំដោយប្រធានមួយរូបដែលមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

## ជំពូកទី ៧

## អគ្គនាយកដ្ឋាន អភិវឌ្ឍសង្គម

**មាត្រា ១៥.-**

អគ្គនាយកដ្ឋានអភិវឌ្ឍសង្គម មានភារកិច្ចធ្វើជាសេនាធិការជូនក្រសួងលើការងារ :

-ទំនាក់ទំនងសម្របសម្រួល គ្រប់គ្រងការងារពាក់ព័ន្ធនិងការការពារផ្លូវច្បាប់ លើកកម្ពស់សុខភាពនិងការអប់រំស្ត្រី

-អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ជូន ។

អគ្គនាយកដ្ឋានអភិវឌ្ឍសង្គម ដឹកនាំដោយអគ្គនាយកមួយរូបដែលមានអគ្គនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានអភិវឌ្ឍសង្គម មាននាយកដ្ឋានចំណុះចំនួន ៣ ដូចខាងក្រោម ៖

-នាយកដ្ឋាន ការពារផ្លូវច្បាប់

-នាយកដ្ឋាន ស្ត្រីនិងសុខភាព

-នាយកដ្ឋាន ស្ត្រីនិងការអប់រំ

**មាត្រា ១៦.-**

**នាយកដ្ឋាន ការពារផ្លូវច្បាប់ មានភារកិច្ច ៖**

-រៀបចំគោលការណ៍ និងគោលនយោបាយដើម្បីការពារផ្លូវច្បាប់ ដល់ ស្ត្រី និងក្មេងស្រី

-រៀបចំ តាក់តែង សេចក្តីព្រាងច្បាប់ និងធ្វើវិសោធនកម្មលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធផ្សេងៗដើម្បីការពារ ស្ត្រី ក្មេងស្រី ឱ្យចាកផុតពីអំពើហិង្សា និងការកេងប្រវ័ញ្ច ហើយធានាបាននូវសមភាព និងសមធម៌ យេនឌ័រ

-ចូលរួមផ្តល់យោបល់ក្នុងការតាក់តែងអត្ថបទច្បាប់ដែលរៀបចំដោយស្ថាប័នផ្សេងៗដែលពាក់ព័ន្ធស្ត្រី និងកុមារ

-រៀបចំឱ្យមានជាអនុស្សារណៈនៃការយោគយល់គ្នាជាមួយប្រទេសជិតខាង ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់អំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ និងកិច្ចការពារជនរងគ្រោះ និងតាមដាន ការអនុវត្តច្បាប់ បទប្បញ្ញត្តិ អនុស្សារណៈនានា ឱ្យមានប្រសិទ្ធភាព

-កសាងសមត្ថភាពមន្ត្រី បុគ្គលិកក្រសួងតាំងពីថ្នាក់ជាតិ ដល់ថ្នាក់ខេត្ត-ក្រុង និងក្រសួងពាក់ព័ន្ធ អំពីផ្នែក ច្បាប់ដែលពាក់ព័ន្ធនឹងស្ត្រី និងកុមារនឹងសិទ្ធិមនុស្ស លើមូលដ្ឋាននៃសមភាពយេនឌ័រ ខ្លឹមសារអនុសញ្ញា ពិធីសារ អន្តរជាតិ និងអនុស្សារណៈ នៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការពហុភាគីនានា ដែលពាក់ព័ន្ធដល់ស្ត្រី

-កសាងសមត្ថភាពគ្រូបង្គោលថ្នាក់ជាតិ ថ្នាក់ខេត្ត របស់ក្រសួងកិច្ចការនារី និងក្រសួងពាក់ព័ន្ធ អំពីការទប់ ស្កាត់រាល់រូបភាពនៃអំពើហិង្សាប្រឆាំងនឹងស្ត្រី និងជំនាញពិគ្រោះយោបល់ផ្នែកច្បាប់ និងផ្នែកចិត្តសាស្ត្រ

-សម្របសម្រួល ដើម្បីស្វែងរកការប្រឹក្សាយោបល់ផ្នែកច្បាប់ ផ្នែកចិត្តសាស្ត្រដល់ជនរងគ្រោះ និងបញ្ជូនបន្ត ទៅសេវានានារបស់អង្គការក្រៅរដ្ឋាភិបាលដែលអាចជួយពួកគេបាន

-សម្របសម្រួល និងជំរុញអន្តរាគមន៍តាមផ្លូវច្បាប់ ដល់ជនរងគ្រោះដោយការជួញដូរ ដោយអំពើហិង្សាក្នុង គ្រួសារ ដោយការចាប់រំលោភសេពសន្ថវៈ ឬដោយការរំលោភបំពានដទៃទៀត

-ធ្វើជាអ្នកដើមបណ្តឹងជួសមុខឱ្យជនរងគ្រោះទៅតុលាការ

-អប់រំផ្សព្វផ្សាយ បង្កើនការយល់ដឹងអំពីគ្រោះថ្នាក់ និងផលវិបាកនៃអំពើហិង្សាប្រឆាំងនឹងស្ត្រី និងការជួញដូរ ផ្លូវភេទ

-ទំនាក់ទំនង និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ អ្នកផ្តល់ ជំនួយ ដើម្បីអនុវត្តនិងរក្សានិរន្តរភាពការងារផ្នែកការពារផ្លូវច្បាប់ ជាពិសេសការធ្វើអន្តរាគមន៍ជួយជនរងគ្រោះ ។

នាយកដ្ឋានការពារផ្លូវច្បាប់ ដឹកនាំដោយប្រធានមួយរូបដែលមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

**មាត្រា ១៧.-**

**នាយកដ្ឋាន ស្ត្រីនិងសុខភាព** មានភារកិច្ច :

-ធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាព ស្ត្រី កុមារ មាតានិងទារក ដោយផ្តល់ព័ត៌មាន ស្តីពីសុខភាពអនាម័យ អាហារូបត្ថម្ភ ធ្វើការផ្សព្វផ្សាយអប់រំ អំពីសិទ្ធិ និងលទ្ធភាពទទួលបាននូវសេវាថែទាំសុខភាព ដែលមានសុវត្ថិភាព ដោយសហការជាមួយក្រសួងពាក់ព័ន្ធ និងផ្តល់ការបណ្តុះបណ្តាលដល់អ្នកស្ម័គ្រចិត្តតាមបណ្តាខេត្ត-ក្រុង និងសហគមន៍នានាដើម្បីធ្វើការងារនេះ

-ស្វែងរកការគាំទ្រពីថ្នាក់ដឹកនាំរបស់ស្ថាប័នពាក់ព័ន្ធ បញ្ចូលទៅក្នុងផែនការសកម្មភាពរបស់ក្រសួង-ស្ថាប័នទាំងឡាយ នូវការលើកកម្ពស់ យុទ្ធសាស្ត្របញ្ច្រាបយេនឌ័រ ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺអេដស៍ ការថែទាំ និងការគាំទ្រ ដល់អ្នកផ្ទុក មេរោគអេដស៍

-ចរចា និងតស៊ូមតិ ដើម្បីឱ្យស្ថាប័នពាក់ព័ន្ធអនុវត្តគោលនយោបាយ និងសេចក្តីណែនាំ អំពីការផ្តល់សេវាសុខភាពដោយឥតគិតថ្លៃ និងប្រើប្រាស់មូលនិធិសមធម៌

-ពង្រឹងសមត្ថភាពមន្ត្រី បុគ្គលិករបស់ក្រសួង និងក្រុមជំនាញមកពីក្រសួងស្ថាប័នពាក់ព័ន្ធ ឱ្យយល់ពីសិទ្ធិរបស់ស្ត្រី កុមារ ដើម្បីទទួលនូវសេវាថែទាំសុខភាពបឋម ជាពិសេសសុខភាពបន្តពូជ

-ត្រួតពិនិត្យនិងវាយតម្លៃកម្មវិធីសុខភាពស្ត្រី និងកុមារ ។

នាយកដ្ឋានស្ត្រីនិងសុខភាព ដឹកនាំដោយប្រធានមួយរូបដែលមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

**មាត្រា ១៨.-**

**នាយកដ្ឋាន ស្ត្រីនិងការអប់រំ** មានភារកិច្ច :

-ផ្សព្វផ្សាយ អប់រំ អំពីសារៈសំខាន់ នៃការអប់រំសម្រាប់ស្ត្រីនិងក្មេងស្រី សារៈសំខាន់នៃការថែទាំទារកនិងកុមារ ទាំងរាងកាយ និងបញ្ញាស្មារតី ព្រមទាំងបង្កើនការយល់ដឹងអំពីសិទ្ធិកុមារ និងសិទ្ធិស្ត្រីក្នុងការទទួលនូវការអប់រំ

-សហការជាមួយក្រសួងអប់រំយុវជននិងកីឡា អង្គការ ស្ថាប័នជាតិ និងអង្គការអន្តរជាតិ ដើម្បីបន្តអភិវឌ្ឍគោលនយោបាយ និងកម្មវិធីអប់រំកុមារតូច លើកកម្ពស់ការអប់រំរបស់កុមារី អក្ខរកម្មនិងការអប់រំក្រៅប្រពន្ធ័ រួមមានការផ្តល់អាហារូបករណ៍ និងកម្មវិធីផ្តល់អាហារតាមសាលារៀន

-សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីបង្កើត និងគ្រប់គ្រងអន្តេវាសិកដ្ឋាន សម្រាប់សិស្សស្រីនិងទារកដ្ឋាន

-សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ជ្រើសរើសអ្នកស្ម័គ្រចិត្តធ្វើជាគ្រូអក្ខរកម្ម និងអ្នកថែទាំកុមារ ដែលមានជំនាញ និងរៀបចំការបំប៉នសមត្ថភាពបច្ចេកទេសទៅតាមតម្រូវការជាក់ស្តែង

-សម្របសម្រួលក្នុងការបើកថ្នាក់អក្ខរកម្មនិងកន្លែងថែទាំកុមារ នៅតាមភូមិគោលដៅនិងមជ្ឈមណ្ឌលអភិវឌ្ឍស្ត្រី

នាយកដ្ឋានស្ត្រីនិងការអប់រំ ដឹកនាំដោយប្រធានមួយរូបដែលមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

## ជំពូកទី ៨
## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា ១៩.-**

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌនៃបទប្បញ្ញត្តិកំណត់ក្នុងអនុក្រឹត្យលេខ ៨១អនក្រ.បក ចុះថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យ ហិរញ្ញវត្ថុ លើការចំណាយថវិកានៅតាមបណ្តាក្រសួង ។

## ជំពូកទី ៩
## អង្គភាពមូលដ្ឋាន

**មាត្រា ២០.-**

នៅតាមខេត្ត ក្រុងនិមួយៗ មានមន្ទីរកិច្ចការនារី ដែលទទួលបន្ទុកអនុវត្ត និង សម្របសម្រួលសកម្មភាពរបស់ក្រសួង ។

នៅតាមស្រុក ខណ្ឌនិមួយៗមានការិយាល័យកិច្ចការនារី ដែលទទួលបន្ទុកអនុវត្ត និងសម្របសម្រួលសកម្មភាពរបស់ក្រសួង ។

**មាត្រា ២១.-**

នៅថ្នាក់ខេត្ត-ក្រុង មានមជ្ឈមណ្ឌលអភិវឌ្ឍស្ត្រី សម្រាប់ការផ្តល់សេវាអភិវឌ្ឍន៍សហគ្រាស ជំនាញបច្ចេកទេស គ្រប់គ្រង កម្មវិធីអក្ខរកម្ម និង ជំនាញបំណិនជីវិត ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ២២.-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ។

**មាត្រា ២៣.-**

រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ត្រូវសហការ ជាមួយប្រធានស្ថាប័នពាក់ព័ន្ធដទៃ ដើម្បីបែងចែកការទទួលខុសត្រូវ និងការអនុវត្តភារកិច្ចទាំងឡាយណាដែលពាក់ព័ន្ធតាមប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងប្រធានស្ថាប័នទាំងនោះ ។

**មាត្រា ២៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីនិងរដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត ក្រុង
- ដូចមាត្រា ២៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ខែ កុម្ភៈ ឆ្នាំ២០០៥

## អង្គការលេខរបស់ក្រសួងកិច្ចការនារី



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៩៤ អនក្រ-បក

# អនុក្រឹត្យ

## ស្តីពី

## ការដាក់អោយមន្ត្រីរាជការចូលនិវត្តន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ០៦ ខែសីហា ឆ្នាំ ២០០២ ស្តីពីការគ្រប់គ្រងដំណើរការ នៃការដាក់មន្ត្រីរាជការស៊ីវិល អោយចូលនិវត្តន៍តាមអាយុ តាមប្រព័ន្ធពតិមានវិទ្យា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានដាក់អោយចូលនិវត្តន៍នូវមន្ត្រីរាជការស៊ីវិល ចំនួន ១៥ រូប ដែលស្ថិតក្នុងឋានន្តរសក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

| | |
|---|---|
| ១- លោក **សៅ សារឿន** | ឋានន្តរសក្តិវរមន្ត្រី ថ្នាក់លេខ ២ |
| ២- លោក **ជី ឃួត** | ឋានន្តរសក្តិវរមន្ត្រី ថ្នាក់លេខ ២ |
| ៣- លោក **ស្រី មណ្ឌល** | ឋានន្តរសក្តិវរមន្ត្រី ថ្នាក់លេខ ២ |

៤- លោក គឹម ឆលាំង បានន្តរសក្តិវរមន្ត្រី ថ្នាក់លេខ ២

៥- លោក ម៉ាល់ សំអឿន បានន្តរសក្តិវរមន្ត្រី ថ្នាក់លេខ ២

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ . ថ្ងៃទី ... ឆ្នាំ ២០០៥*

**ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចក្នុងមាត្រា ១ និងមាត្រា ៣*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ....៩៥.....អនក្រ.....បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ហាមនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ អភិបាលខេត្តបាត់ដំបង

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ហាមនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន នៅក្នុង និង ក្រៅប្រទេស ចំនួន ០៦រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាង ព្រះវិហារ នៅក្នុង វត្ត ធម្មជោតារាម ហៅ វត្តទំពូង ឃុំទំពូង ស្រុកថ្មគោល ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោមនេះ :-

**ក.មេដាយមាសស្ហាមនាជាតិ :**

១-ឧបាសិកា **ព្រះ ឈៀង** សប្បុរសជននៅសហរដ្ឋអាមេរិក ថវិកា ចំនួន ១៦.៣១២ ដុល្លារ
២-ឧបាសិកា **ឌឹម សារី** សប្បុរសជននៅសហរដ្ឋអាមេរិក ថវិកា ចំនួន ១២.១៦៥ ដុល្លារ

**ខ.មេដាយប្រាក់ស្ហាមនាជាតិ :**

១-លោក **មាន់ សារុន្ទ** និងអ្នកស្រី **នួម សៀន** សប្បុរសជននៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៩.៤៥០ ដុល្លារ
២-លោក **យឹម យ៉េង** សប្បុរសជននៅ ស្រុកថ្មគោល ខេត្តបាត់ដំបង ថវិកា ចំនួន ៩.៣០០ ដុល្លារ
៣-លោក **សាំង ញ៉ឹង** សប្បុរសជននៅ ស្រុកថ្មគោល ខេត្តបាត់ដំបង ថវិកា ចំនួន ៩.២៦៨ ដុល្លារ
៤-លោក **សៅ មាន់** និងអ្នកស្រី ម៉ុំ សប្បុរសជននៅ ស្រុកថ្មគោល ខេត្តបាត់ដំបង ថវិកា ចំនួន ៩.០២០ ដុល្លារ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។៚

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ... ឆ្នាំ២០០៥

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច ✓
A.244 -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៧ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការស៊ីវិលនៅក្នុងសាលាក្រុងភ្នំពេញ ចំនួន ១២៤ រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចកន្លងមក ដូចមានរាយនាមខាងក្រោមនេះ :

**ក- មេដាយមាសការងារ :**

| | | |
|---|---|---|
| ១-លោក | **សុខ សម្បត្តិ** | អភិបាលខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| ២-លោក | **គួច ចំរើន** | អភិបាលខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| ៣-លោក | **ទៀង សុខុម** | នាយរងខុទ្ទកាល័យសាលាក្រុងភ្នំពេញ |
| ៤-លោក | **ម៉េង ចន្ថា** | នាយរងខុទ្ទកាល័យសាលាក្រុងភ្នំពេញ |
| ៥-លោកស្រី | **គីម ចន្ទ្រធីតា** | នាយរងខុទ្ទកាល័យសាលាក្រុងភ្នំពេញ |
| ៦-លោក | **ម៉ែន ស៊ី** | អភិបាលរងខណ្ឌទួលគោក រាជធានីភ្នំពេញ |
| ៧-លោក | **អេង ខួន** | អភិបាលរងខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| ៨-លោក | **ម៉ែម ណាន** | អភិបាលរងខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| ៩-លោក | **សោម សុវណ្ណ** | អភិបាលរងខណ្ឌ ៧មករា រាជធានីភ្នំពេញ |
| ១០-លោក | **យ៉ិន ខួនគ្រូលេចិន** | អភិបាលរងខណ្ឌ ៧មករា រាជធានីភ្នំពេញ |
| ១១-លោក | **គិត សុផា** | អភិបាលរងខណ្ឌ ដង្កោ រាជធានីភ្នំពេញ |

| | | |
|---|---|---|
| ១២-លោក | កែប សុភា | អភិបាលរងខណ្ឌ ដង្កោ រាជធានីភ្នំពេញ |
| ១៣-លោក | ចិ សោភ័ណ | អភិបាលរងខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| ១៤-លោក | នួន គីមឈេង | អភិបាលរងខណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ |
| ១៥-លោក | ម៉ម យុង | ប្រធានការិយាល័យបុគ្គលិក សាលាក្រុងភ្នំពេញ |
| ១៦-លោកស្រី | ជា សុគន្ធ | អនុប្រធានការិយាល័យបុគ្គលិក សាលាក្រុងភ្នំពេញ |
| ១៧-លោកស្រី | ស៊ឹម ធូលី | ប្រធានការិយាល័យពិធីការ សាលាក្រុងភ្នំពេញ |
| ១៨-លោក | ម៉ុក សំណាង | អនុប្រធានការិយាល័យសរុប សាលាក្រុងភ្នំពេញ |
| ១៩-លោក | ឆេង [illegible] | អនុប្រធានការិយាល័យសរុប សាលាក្រុងភ្នំពេញ |
| ២០-លោក | អ៊ុក សុផល | អនុប្រធានការិយាល័យគណនេយ្យ សាលាក្រុងភ្នំពេញ |
| ២១-លោក | ស៊ូ ផាន់ណារ៉ា | អនុប្រធានការិយាល័យរដ្ឋបាល សាលាក្រុងភ្នំពេញ |
| ២២-លោក | ឈី សារ៉េត | មន្ត្រីសាលាក្រុងភ្នំពេញ |
| ២៣-លោក | យុន ចន្ថា | មន្ត្រីសាលាក្រុងភ្នំពេញ |
| ២៤-លោក | ង៉ែន សុខេម | ប្រធានមន្ទីរខណ្ឌចំការមន រាជធានីភ្នំពេញ |
| ២៥-លោក | នុយ ប៊ុនសេរីវុទ្ធី | អនុប្រធានមន្ទីរខណ្ឌចំការមន រាជធានីភ្នំពេញ |
| ២៦-លោក | ឡុង គីមយាន | អនុប្រធានមន្ទីរខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| ២៧-លោកស្រី | កែប ចន្ទស៊ីនណារី | អនុប្រធានមន្ទីរខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ |
| ២៨-កញ្ញា | កែប សំបូរ | ប្រធានការិយាល័យសាលាខណ្ឌចំការមន រាជធានីភ្នំពេញ |
| ២៩-លោកស្រី | សួន ចាន់ណារី | ប្រធានការិយាល័យសាលាខណ្ឌទួលគោក រាជធានីភ្នំពេញ |
| ៣០-លោក | ជាតិ ជោតិ | អនុប្រធានការិយាល័យសាលាខណ្ឌដង្កោ រាជធានីភ្នំពេញ |
| ៣១-លោក | ឈឹម ឆេងឈី | មន្ត្រីសាលាខណ្ឌចំការមន រាជធានីភ្នំពេញ |

**ខ. មេដាយប្រាក់ការងារ :**

| | | |
|---|---|---|
| ១-លោក | គីម ឈុនអ៊ូ | អភិបាលរងខណ្ឌចំការមន រាជធានីភ្នំពេញ |
| ២-លោក | កែត ស៊ីថិនី | ប្រធានការិយាល័យសាលាក្រុងភ្នំពេញ |
| ៣-លោក | ចំរូ តារាមុន | អនុប្រធានការិយាល័យសាលាក្រុងភ្នំពេញ |
| ៤-លោក | សូ សិទ្ធិ | អនុប្រធានការិយាល័យសាលាក្រុងភ្នំពេញ |
| ៥-លោក | អៀង មូននី | អនុប្រធានការិយាល័យសាលាក្រុងភ្នំពេញ |
| ៦-លោក | អោ ជ្ជមុនី | អនុប្រធានការិយាល័យសាលាក្រុងភ្នំពេញ |
| ៧-លោកស្រី | គ្រួយ សុគន្ធ | អនុប្រធានការិយាល័យសាលាក្រុងភ្នំពេញ |
| ៨-លោក | គុប សីហា | អនុប្រធានការិយាល័យសាលាក្រុងភ្នំពេញ |
| ៩-លោក | ឈរាង ចាន់ | មន្ត្រីសាលាក្រុងភ្នំពេញ |
| ១០-លោក | ព្រាក់ ជោតមាលិត | មន្ត្រីសាលាក្រុងភ្នំពេញ |
| ១១-លោកស្រី | គីម សេដ្ឋានី | មន្ត្រីសាលាក្រុងភ្នំពេញ |
| ១២-កញ្ញា | មឿង សុភ័ក្ត្រា | មន្ត្រីសាលាក្រុងភ្នំពេញ |
| ១៣-លោក | ឃួត ចំរើន | ជំនួយការឯកឧត្តមអភិបាលរងរាជធានីភ្នំពេញ |

| | | |
|---|---|---|
| ១៤-លោក | សៅ ពេជ្រា | មន្ត្រីសាលាក្រុងភ្នំពេញ |
| ១៥-លោក | សំ ស៊ីផុក | មន្ត្រីសាលាក្រុងភ្នំពេញ |
| ១៦-លោក | អំ ហ៊ៀន | ប្រធានការិយាល័យសាលាខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| ១៧-លោក | មុត សារ៉ាវុធ | អនុប្រធានការិយាល័យសាលាខណ្ឌដូនពេញរាជធានីភ្នំពេញ |
| ១៨-លោក | ស៊ុម ឈាំ | អនុប្រធានការិយាល័យសាលាខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| ១៩-លោក | អ៊ុ សុជាតិ | ប្រធានផ្នែកបុគ្គលិកសាលាខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| ២០-លោក | អ៊ុច កេសរ៉ា | មន្ត្រីសាលាខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| ២១-លោក | ម៉ុន សារឿន | អនុប្រធានការិយាល័យសាលាខណ្ឌចំការមនរាជធានីភ្នំពេញ |
| ២២-លោក | តាម សារ៉េន | មន្ត្រីសាលាខណ្ឌចំការមន រាជធានីភ្នំពេញ |
| ២៣-លោក | ឧក សុផានៃ | មន្ត្រីសាលាខណ្ឌចំការមន រាជធានីភ្នំពេញ |
| ២៤-លោក | អ៊ូ សាន | មន្ត្រីសាលាខណ្ឌចំការមន រាជធានីភ្នំពេញ |
| ២៥-លោកស្រី | ម៉ែន សុធា | មន្ត្រីសាលាខណ្ឌចំការមន រាជធានីភ្នំពេញ |
| ២៦-លោក | ព្រាក់ ចាន់ណា | ប្រធានការិយាល័យសាលាខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ |
| ២៧-លោក | គឹម សុខលី | ប្រធានផ្នែកអត្រានុកូលដ្ឋានខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ |
| ២៨-លោក | គង់ សារុន | មន្ត្រីសាលាខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ |
| ២៩-លោក | នៃ ឈឺត | ប្រធានការិយាល័យសាលាខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| ៣០-លោក | យឹម ឃ្លីង | មន្ត្រីសាលាខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| ៣១-កញ្ញា | ស៊ុន មូរ៉ា | មន្ត្រីសាលាខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| ៣២-លោក | ស៊ុយ សារ៉ាន់ | មន្ត្រីសាលាខណ្ឌ៧មករា រាជធានីភ្នំពេញ |
| ៣៣-លោក | យូ ផ្លោ | មន្ត្រីសាលាខណ្ឌ៧មករា រាជធានីភ្នំពេញ |
| ៣៤-លោក | ឈឹម ឈុន | មន្ត្រីសាលាខណ្ឌ៧មករា រាជធានីភ្នំពេញ |
| ៣៥-លោក | សាំង អ៊ីម | មន្ត្រីសាលាខណ្ឌទួលគោក រាជធានីភ្នំពេញ |
| ៣៦-លោក | ម៉ាន់ ឈួរ | មន្ត្រីសាលាខណ្ឌទួលគោក រាជធានីភ្នំពេញ |
| ៣៧-លោក | ឈៀម សុនី | មន្ត្រីសាលាខណ្ឌទួលគោក រាជធានីភ្នំពេញ |
| ៣៨-លោក | គង់ សំណាង | ប្រធានផ្នែកអត្រានុកូលដ្ឋានខណ្ឌដង្កោ រាជធានីភ្នំពេញ |
| ៣៩-លោក | ឈឹម សុផល | មន្ត្រីសាលាខណ្ឌដង្កោ រាជធានីភ្នំពេញ |

**ឆ. មេជាងសំណង់ការងារ :**

| | | |
|---|---|---|
| ១-លោក | យុំ ណាង | មន្ត្រីសាលាក្រុងភ្នំពេញ |
| ២-លោក | មុត សុមង្គល | ជំនួយការឯកឧត្តមអភិបាលរងរាជធានីភ្នំពេញ |
| ៣-លោក | សៀក សុខ | មន្ត្រីសាលាក្រុងភ្នំពេញ |
| ៤-លោក | កែម ចន្ទរតនៈ | មន្ត្រីសាលាក្រុងភ្នំពេញ |
| ៥-លោក | កែម ជាទី | មន្ត្រីសាលាក្រុងភ្នំពេញ |
| ៦-កញ្ញា | ចេង ចិន្តា | មន្ត្រីសាលាក្រុងភ្នំពេញ |
| ៧-លោកស្រី | សុខ ចន្ទីមារី | មន្ត្រីសាលាក្រុងភ្នំពេញ |

| | | |
|---|---|---|
| ៨-លោកស្រី | គឹម សុផាវី | មន្ត្រីសាលាក្រុងភ្នំពេញ |
| ៩-លោកស្រី | មេង សុភា | មន្ត្រីសាលាក្រុងភ្នំពេញ |
| ១០-លោកស្រី | អាច ចាន់នី | មន្ត្រីសាលាក្រុងភ្នំពេញ |
| ១១-លោកស្រី | យ៉ាង [illegible] | មន្ត្រីសាលាក្រុងភ្នំពេញ |
| ១២-លោកស្រី | ម៉ៀង [illegible] | មន្ត្រីសាលាក្រុងភ្នំពេញ |
| ១៣-កញ្ញា | អ៊ុម [illegible] | មន្ត្រីសាលាក្រុងភ្នំពេញ |
| ១៤-កញ្ញា | ពុយ [illegible] | មន្ត្រីសាលាក្រុងភ្នំពេញ |
| ១៥-លោក | ពុទ្ធ ពុធ | មន្ត្រីសាលាក្រុងភ្នំពេញ |
| ១៦-លោក | ប្រាម ទី | មន្ត្រីសាលាក្រុងភ្នំពេញ |
| ១៧-លោក | មៀន សារិទ្ធ | មន្ត្រីសាលាក្រុងភ្នំពេញ |
| ១៨-លោក | ផល សារ៉ាត់ | មន្ត្រីសាលាក្រុងភ្នំពេញ |
| ១៩-លោក | ប្រាក់ ច័ន្ទសម្បត្តិ | មន្ត្រីសាលាក្រុងភ្នំពេញ |
| ២០-លោក | ម៉ៅ សារ៉ែ | មន្ត្រីសាលាក្រុងភ្នំពេញ |
| ២១-លោក | ឡុយ សុវណ្ណ | មន្ត្រីសាលាខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| ~~២២-លោក~~ | ~~ឈុន សេង~~ | ~~អនុប្រធានផ្នែកវិវាទសាលាខណ្ឌដូនពេញ រាជធានីភ្នំពេញ~~ |
| ២៣-លោកស្រី | សៀម ផ្កាតារាវី | មន្ត្រីសាលាខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| ២៤-លោក | មាស ដាច | អនុប្រធានផ្នែករបៀបសាលាខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| ២៥-លោក | ឌួន សុខុម | មន្ត្រីសាលាខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| ២៦-លោក | ម៉ែន កុសលស្នើ | មន្ត្រីសាលាខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| ២៧-លោកស្រី | សាន់ ច័ន្ទធារា | មន្ត្រីសាលាខណ្ឌទួលគោក រាជធានីភ្នំពេញ |
| ២៨-លោក | គៅ សំអុល | មន្ត្រីសាលាខណ្ឌទួលគោក រាជធានីភ្នំពេញ |
| ២៩-កញ្ញា | ហ៊ុន សាវី | មន្ត្រីសាលាខណ្ឌទួលគោក រាជធានីភ្នំពេញ |
| ៣០-លោក | ជា សារី | អនុប្រធានផ្នែកអត្រានុកូលដ្ឋានខណ្ឌទួលគោក រាជធានីភ្នំពេញ |
| ៣១-លោក | សុខ សេង | មន្ត្រីសាលាខណ្ឌ៧មករា រាជធានីភ្នំពេញ |
| ៣២-លោក | សុខ ច័ន្ទធា | មន្ត្រីសាលាខណ្ឌ៧មករា រាជធានីភ្នំពេញ |
| ៣៣-លោក | សេន សុភា | មន្ត្រីសាលាខណ្ឌ៧មករា រាជធានីភ្នំពេញ |
| ៣៤-កញ្ញា | យ៉ឹម ប៊ុនធា | មន្ត្រីសាលាខណ្ឌ៧មករា រាជធានីភ្នំពេញ |
| ៣៥-លោក | សម សម្ផា | មន្ត្រីសាលាខណ្ឌ៧មករា រាជធានីភ្នំពេញ |
| ៣៦-លោក | ជា សុត | អនុប្រធានផ្នែកសាលាខណ្ឌចំការមន រាជធានីភ្នំពេញ |
| ៣៧-លោក | ហ៊ួត សុខន | មន្ត្រីសាលាខណ្ឌចំការមន រាជធានីភ្នំពេញ |
| ៣៨-លោកស្រី | ឆ៊ិន សារិន | មន្ត្រីសាលាខណ្ឌចំការមន រាជធានីភ្នំពេញ |
| ៣៩-លោកស្រី | ហ៊ុន សុវណ្ណឌី | មន្ត្រីសាលាខណ្ឌចំការមន រាជធានីភ្នំពេញ |
| ៤០-លោក | ឆៀង ស្រ៊ាង | អនុប្រធានផ្នែកសាលាខណ្ឌចំការមន រាជធានីភ្នំពេញ |
| ៤១-លោក | ឌិន គឹមគ្រី | អនុប្រធានផ្នែកសាលាខណ្ឌចំការមន រាជធានីភ្នំពេញ |

| | | |
|---|---|---|
| ៤២-លោក | អ៊ុច សំអឿន | អនុប្រធានផ្នែកសាលាខណ្ឌចំការមន រាជធានីភ្នំពេញ |
| ៤៣-លោក | សែម សុគន្ធា | មន្ត្រីសាលាខណ្ឌចំការមន រាជធានីភ្នំពេញ |
| ៤៤-លោក | ថា ណារិន | មន្ត្រីសាលាខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| ៤៥-លោក | ឈន សុវណ្ណ | ប្រធានផ្នែកសាលាខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| ៤៦-លោក | សេង [illegible] | ស្មៀនសង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| ៤៧-លោក | [illegible] សំអឿន | ស្មៀនសង្កាត់ផ្សារដើមថ្កូវ ខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| ៤៨-កញ្ញា | [illegible] | មន្ត្រីសាលាខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ |
| ៤៩-អ្នកស្រី | យិន សំអាន | ប្រធានផ្នែកសាលាខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ |
| ៥០-លោក | ឡាច ម៉ុនតេជា | ស្មៀនប្រចាំការសាលាខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ |
| ៥១-លោក | សម ហ៊ុន | ប្រធានការិយាល័យសាលាខណ្ឌដង្កោ រាជធានីភ្នំពេញ |
| ៥២-លោក | ប៉ិយ ប៉ិនិត | អនុប្រធានផ្នែកអត្រានុកូលដ្ឋានខណ្ឌដង្កោ រាជធានីភ្នំពេញ |
| ៥៣-លោក | ជុំ ផន | ប្រធានផ្នែកសាលាខណ្ឌដង្កោ រាជធានីភ្នំពេញ |
| ៥៤-លោក | ឆាន ចំរើន | មន្ត្រីសាលាខណ្ឌដង្កោ រាជធានីភ្នំពេញ |

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ [illegible] ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**......៧៧......អនក្រ.តត

# អនុក្រឹត្យ
# ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤/ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១:** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូនលោកវរសេនីយ៍ទោ **ឈួន ដារី** អត្តលេខ ០៥៥១ អនុប្រធានអធិការដ្ឋានកិច្ចការនគរបាលនៃអគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និងនគរបាល ក្រសួងមហាផ្ទៃ ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ខែ កុម្ភៈ ឆ្នាំ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៥៨ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៩/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

**សម្រេច**

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០២គ្រឿង ជូនក្រុមបច្ចេកទេសប្រតិបត្តិគំរោងសិក្សាមូលដ្ឋាន នៃ ការកសាងបង្គោលប្រឹថពីវិភាគ នៅកម្ពុជា ដែលបានអនុវត្តរយៈពេល ១០ខែ នៅក្នុងនិងតំបន់ជុំវិញខេត្តកំពង់ឆ្នាំង មានទឹកប្រាក់សរុបចំនួន ៩៧០.០០០ ដុល្លារ ដូចមានរាយនាមខាងក្រោមនេះ :-

១-លោក KANG MOON SUN

២-លោក CHO KYU CHAN

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋអម
## ទូរគមនាគមន៍កម្ពុជា

៙

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ
- យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា១:** តែងតាំងលោក **ទាវ សុធី** ប្រធាននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាមន្ត្រីត្រួតពិនិត្យរដ្ឋអមទូរគមនាគមន៍កម្ពុជា សំរាប់អាណត្តិ ៣ ឆ្នាំ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទូរគមនាគមន៍កម្ពុជា
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១០០ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

## សម្រេច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនលោក **CHO SUNG TAE** ប្រធានក្រុមហ៊ុន **SAMBOO Engineering Co.Ltd** នៃ សាធារណរដ្ឋកូរ៉េ ដែលបានផ្តួចផ្តើមកសាងគំរោងសិក្សាមូលដ្ឋាន នៃ ការកសាងបង្គោលប្រឹថពីវិភាគ នៅកម្ពុជា មានទឹកប្រាក់សរុបចំនួន ៩៧០.០០០ ដុល្លារ ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល** :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

B.77

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១០១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា .

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេនព្រះសង្ឃ និង ជូនសប្បុរសជន ចំនួន១៣រូប ដែលបានបរិច្ចាគបច្ច័យ និង ធនធាន ជួយកសាងសមិទ្ធផលសាធារណៈ នានា លើវិស័យព្រះពុទ្ធសាសនា អប់រំ និង សង្គមកិច្ច នៅស្រុកកងមាស ខេត្តកំពង់ចាម ដូចមានរាយព្រះនាម និង នាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

១-ព្រះគ្រូ **ពេជ្រ សុភាព** អនុគណស្រុកកងមាស និង ជាចៅអធិការ វត្ត កងតាណឹង បច្ច័យ ចំនួន ២១.០០០ ដុល្លារ

២-ព្រះគ្រូ **យុន ម៉ុនសុន** លេខាធិការស្រុកកងមាស និង ជាចៅអធិការ វត្ត ថ្មុកជ្រៅ បច្ច័យ ចំនួន ១៩.៥០០ ដុល្លារ

៣-ព្រះគ្រូ **ឆាយ ឌុំ** ធម្មធរស្រុកកងមាស និង ជាចៅអធិការ វត្ត ស្ពោលើ បច្ច័យ ចំនួន ១៨.២០០ ដុល្លារ

៤-ព្រះគ្រូ **ស្រ៊ាង ម៉ុក** វិន័យធរស្រុកកងមាស និង ជាចៅអធិការ វត្ត កែវមុនី បច្ច័យ ចំនួន ១៥.៧៥០ ដុល្លារ

៥-ព្រះគ្រូ **មិន គី** ចៅអធិការ វត្តវារិន្ទ បច្ច័យ ចំនួន ១២.៣០០ ដុល្លារ

៦-ព្រះគ្រូ **សំ ម៉ុនឡៀន** ចៅអធិការ វត្តព្រែកក្របៅ បច្ច័យ ចំនួន ១២.២០០ ដុល្លារ

៧-ព្រះគ្រូ **ឃុត ញ៉ឹ** ចៅអធិការ វត្តនិគ្រោធ បច្ច័យ ចំនួន ១១.៨០០ ដុល្លារ

៨-ព្រះគ្រូ ម៉ៅ សុខន ចៅអធិការ វត្តរការអារ បច្ច័យ ចំនួន ១១.៥០០ ដុល្លារ

៩-ឯកឧត្តម អ៊ុត ឃ្លាំង រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ថវិកា ចំនួន ២០.០០០ ដុល្លារ

១០-ឯកឧត្តម ម៉ៅ តិរុណ អភិបាលរងទី២ ខេត្តកំពង់ចាម ថវិកា ចំនួន ១០.០០០ ដុល្លារ

១១-លោក ម៉ែន ស៊ីផាន់ អគ្គនាយកចំការកៅស៊ូពាមជាំង ថវិកា ចំនួន ១០.០០០ ដុល្លារ

**ខ-មេដាយស្ថាបនាជាតិ :**

១-លោក ខែម ស៊ុនមោច មន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ថវិកា ចំនួន ៣.៣២០ ដុល្លារ

២-លោក ឃួន ម៉ានី ប្រធានតុលាការក្រុងព្រះសីហនុ ថវិកា ចំនួន ៣.៤១០ ដុល្លារ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ x+

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

B..75-76

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១០៨ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

**ស ម្រេ ច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០២រូប ដែលបានផ្តល់ថវិកាជួយកសាងសាលារៀន នៅ ខេត្តរតនគិរី ដូចមានរាយនាមខាងក្រោម :-

១-លោក ***Bernard Krisher*** ប្រធានអង្គការ ***AAFC*** បានផ្តល់ថវិកា ចំនួន ១២.០០០ ដុល្លារ ជួយសាងសង់អគារសិក្សាមួយខ្នង នៅឃុំតាឡាវ ស្រុកអណ្តូងមាស ខេត្តរតនគិរី ។

២-លោក ***Henry Jarecki*** បានផ្តល់ថវិកា ចំនួន ២០.០០០ ដុល្លារ ជួយសាងសង់អគារសិក្សាមួយខ្នង នៅភូមិកាន់តងណងឡិ ស្រុកអូរជុំ ខេត្តរតនគិរី ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា និង អភិបាលខេត្តរតនគិរី ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ... ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១០៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៣៧

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា .

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សម្រេច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន មួយរូប និង អង្គការក្រៅរដ្ឋាភិបាល មួយ ដែលបានជួយឧបត្ថម្ភដល់វិស័យអប់រំ នៅព្រះរាជាណាចក្រកម្ពុជា ដូចមានខាងក្រោម :-

១-លោកឪពុក *John Visser* ប្រធានអង្គការ *DONBOSCO* បានផ្តល់ថវិកា ចំនួន ៣០.០០០ ដុល្លារអាមេរិក សំរាប់ជួយសាងសង់អគារសិក្សា មួយខ្នង មាន០៦បន្ទប់ និង បង្គន់អនាម័យ ០៨បន្ទប់ ជូនសាលាបឋមសិក្សាស្ទាច់ដែង ខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហានុ ។

២-អង្គការមូលនិធិសង្គ្រោះកុមារ អន្តរជាតិ *ICS* បានផ្តល់ថវិកា ចំនួន ២៣១.១៩៧ ដុល្លារអាមេរិក សំរាប់ជួយសាងសង់អគារសិក្សា សង់ប្រព័ន្ធទឹក ជួសជុលផ្ទះ ផ្តល់មេគោ-ជ្រូក សំភារៈសិក្សា សំលៀកបំពាក់ មុង ភួយ ទោចក្រយាន និង អាហារូបត្ថម្ភ បំរើវិស័យអប់រំ នៅតាមបណ្តាខេត្ត នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

B..77

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ 204 អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

**សម្រេច**

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ១០គ្រឿង ប្រគេន និង ជូនសប្បុរសជន នៅសហរដ្ឋអាមេរិក ចំនួន ១០រូប ដែលបានបរិច្ចាគបច្ច័យ និង ថវិកា ចូលរួមជួយកសាង ព្រះវិហារ កុដិ សាលាឆាន់ របង ក្លោងទ្វារ និង សមិទ្ធផលជាច្រើនទៀត នៅក្នុងពុទ្ធសីមា វត្តទួលអង្គក្រពើ សង្កាត់គោករកា ខណ្ឌដង្កោ រាជធានីភ្នំពេញ ដូចមានរាយព្រះនាម និង នាមខាងក្រោម :-

| | | |
|---|---|---|
| ១-ព្រះតេជគុណ | **សុមង្គលា ឆៃ** | បច្ច័យ ១២.៨០០ ដុល្លារ |
| ២-លោក | **យិន អេខលន់** | ថវិកា ១១.៧៦០ ដុល្លារ |
| ៣-លោក | **ឡារី** | ថវិកា ១០.៥០០ ដុល្លារ |
| ៤-លោក | **នីណៈប្រុតា ម៉ុខ** | ថវិកា ១០.៤៨០ ដុល្លារ |
| ៥-លោកស្រី | **ហោ ម៉ួយ** | ថវិកា ១០.៣៥០ ដុល្លារ |
| ៦-លោក | **សុគន្ធ ឌួច** | ថវិកា ១០.២៥០ ដុល្លារ |
| ៧-លោក | **ខៃ សុន** | ថវិកា ១០.២០០ ដុល្លារ |
| ៨-លោកស្រី | **ផាច សារឿម** | ថវិកា ១០.១៥០ ដុល្លារ |

៩-លោកស្រី [illegible] ថវិកា ១០.០០០ ដុល្លារ

១០-ឧបាសិកា [illegible] ថវិកា ១០.០០០ ដុល្លារ

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល** :
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចក្នុងមាត្រា ១ និង មាត្រា ២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

B.033-34

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ១០៥ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការតែងតាំងជំនួយការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាឱ្យដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- យោងតាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកកម្មវិធីមហាអនុតំបន់មេគង្គ

### សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **ហេង ប៊ុនលី** ជាជំនួយការរបស់ឯកឧត្តម **ឃី តាំងលឹម** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកកម្មវិធីមហាអនុតំបន់មេគង្គ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** ។

